ទៅពួននៅគល់ដើមស្វាយ ដោយធ្វើយ៉ាងណាមិនឲ្យពិចិត្តឃើញខ្ញុំឡើយ។ ខ្ញុំលួចមើលគេ គេដោះសម្លៀកបំពាក់ដើម្បីមុជទឹក... ខ្លួនគេស្គម... ប៉ុន្តែមាឌគេមាំដោយសារឆ្អឹងធំ។ គេមានសម្បុរសណ្តែកបាយ... មើលទៅឃើញថាជាមនុស្សស្លូតបូតណាស់... ទឹកមុខញញឹមជានិច្ច សមជាមនុស្សមិនបង្ករឿងឈ្លោះប្រកែកនឹងនរណាម្នាក់ឡើយ ព្រមទាំងសន្តោសនូវទោសកំហុសរបស់អ្នកផងទាំងពួង។ ខ្ញុំនឹកក្នុងចិត្ត មនុស្សនេះសមជាមនុស្សចិត្តល្អកម្ររកបាន ហើយស្រឡាញ់នូវអំពើយុត្តិធម៌ទៀតផង។ ចំណែកខ្ញុំវិញ ជាមនុស្សនិយាយច្រើនណាស់ ព្រមទាំងមានចរិតកាចបន្តិចផង... ប៉ុន្តែបើនិយាយឲ្យចំ កាចតែចំពោះជនណាអាក្រក់ដែរ បើចំពោះជនស្លូតបូត បែរជាគោរពគេទៅវិញ។ ពិចិត្តឡើងពីត្រពាំង ហើយដើរក្បែរដើមស្វាយតម្រង់ទៅផ្ទះ។ លុះយល់ថា គេលែងមើលឃើញខ្ញុំហើយ ខ្ញុំក៏ចុះទៅមុជទឹកជម្រះកាយម្តង។ ខ្ញុំសង្កេតឃើញពិចិត្តជាមនុស្សមានអនាម័យ ពីព្រោះក្រចកដៃក្រចកជើងគេកាត់តម្រឹមយ៉ាងស្អាត។ ខោអាវដែលគេស្លៀកពាក់ ថ្វីត្បិតតែមានសភាពមិនថ្មីស្រឡាងក៏ដោយ ក៏មើលទៅឃើញស្អាត ដោយសារការបោកគក់ជាញឹកញាប់។ នៅពេលដែលខ្ញុំត្រឡប់ពីត្រពាំងមកដល់ផ្ទះ... ខ្ញុំឥតឃើញពិចិត្តទេ... ខ្ញុំក៏ឡើងទៅលើផ្ទះ ហើយអុជចង្កៀងបំភ្លឺ។ ខ្ញុំអស់កម្លាំងខ្លាំងពេក... ព្រោះកាលពីព្រឹក ខ្ញុំបានធ្វើដំណើរផ្លូវឆ្ងាយ... ពេលល្ងាចប្រជុំ... ហើយពេលហូបបាយ ខ្ញុំហូបបានតែពីរបីម៉ាត់គត់។ ខ្ញុំក៏ប្រញាប់យកកន្ទេលស្លឹកត្នោត មកក្រាលចំកន្លែងដែលពិចិត្តក្រាលកាលពីយប់ទីមួយ។ ដោយត្រូវខ្យល់បក់មករំភើយៗតាមមាត់ទ្វារដែលចំហស្រាប់ ទើបធ្វើឲ្យខ្ញុំលង់លក់ភ្លាមមួយរំពេចដូចគេសណ្តំ។ ពេលភ្ញាក់ឡើង ខ្ញុំហាក់ដឹងថា ខ្ញុំរងាម្ល៉េះ ខ្ញុំឃើញពិចិត្តនៅដេកក្បែរខ្ញុំដែរ តែខ្ញុំមិនដឹងថា គេមកតាំង





ពីម៉ោងប៉ុន្មានទេ។ ខ្ញុំភើចក្រមាដែលខ្ញុំដាក់ខណ្ឌ យកមកលាដណ្តប់... ខ្ញុំនៅតែមិនបាត់រងា។

ពិចិត្តភ្ញាក់ឡើង ហើយសួរខ្ញុំ ៖

- យុនកើតអីហ្នឹង ?

- ខ្ញុំរងាណាស់ !

ខ្ញុំឆ្លើយតបទៅគេបែបដូចជាសុភាពជាងថ្ងៃមុន។ ពិចិត្តយកដៃមកស្ទាបថ្ងាសខ្ញុំ រួចលាន់មាត់ ៖

- យី! ខ្លួនយុនក្តៅណាស់... ច្បាស់ជាបណ្តាលមកពីយុនដួលពីព្រឹកមិញហើយ។

និយាយបណ្តើរ ពិចិត្តងើបដើរទៅយកថ្នាំដែលគេបានលាក់ទុក មកឲ្យខ្ញុំលេបចំនួនពីរគ្រាប់។

កាយវិការដ៏ល្អប្រពៃនេះ ធ្វើឲ្យខ្ញុំកាន់តែកក់ក្តៅខ្លាំងឡើងៗ។ រយៈពេលតែពីរថ្ងៃសោះ អ្វីៗដែលជារបស់ពិចិត្តបានដក់ក្នុងអារម្មណ៍ខ្ញុំឥតភ្លេច... គឺគេគោរពខ្ញុំ... គេថ្នមខ្ញុំ... គេប្រណីខ្ញុំ... ហើយអម្បាញ់មិញនេះ គេព្យាបាលខ្ញុំទៀត... រួចគេយកអាវរបស់គេពីក្នុងស្បោង មកបំពាក់បន្ថែមលើអាវខ្ញុំមួយជាន់ទៀត... រួចយកក្រមារបស់គេមកដណ្តប់ជើងខ្ញុំទាំងពីរ ដើម្បីឲ្យខ្ញុំបានកក់ក្តៅ។ ខ្ញុំបែរជាលែងភ័យខ្លាចពិចិត្តហើយ... តែខ្ញុំបែរជាមានការលំបាកនឹងជំងឺញាំញីទៅវិញ។

ពិចិត្តសួរខ្ញុំទៀត ៖

- យុនបាត់រងាហើយឬនៅ ?

ខ្ញុំឆ្លើយ ៖

- នៅទេ !

មិនដឹងជាគិតយ៉ាងដូចម្ដេច ក៏ស្រាប់តែពិចិត្តស្រវាឱបខ្ញុំយ៉ាងណែនក្នុងរង្វង់ដៃ។ ខ្ញុំស្លន់បាត់មាត់ដូចគេចុក រួចបែកញើស... ខ្ញុំទន់ខ្លួនដូចសំឡី... រកតែរើក៏មិនរួច... ខ្ញុំដឹងថា ពិចិត្តលួចថើបខ្ញុំស្រាលៗ ហើយនិយាយខ្សឹបដាក់ត្រចៀកខ្ញុំ ៖

- ឈ្លបនៅក្រោមផ្ទះយើង។

រួចពិចិត្តបន្តសម្ដីឮខ្លាំងៗ ៖

- ស្រឡាញ់បងទេយុន?

ខ្ញុំភ័យនឹងឈ្លបខ្លាំងពេក ក៏ឆ្លើយតបទៅពិចិត្តទាំងញញីញញ័រថា ៖

- ចាស! ស្រឡាញ់... ស្រឡាញ់... បង។

ប្រហែលជាឮសម្ដីយើងឆ្លើយឆ្លងគ្នាល្អកល្អឺនយ៉ាងដូច្នេះហើយ បានជាខ្ញុំឮសម្រឹបជើងឈ្លបដើរចេញពីផ្ទះខ្ញុំទៅ។ ខ្ញុំនៅតែភិតភ័យពុំស្រាកស្រាន្តសោះ... ណាភ័យនឹងឈ្លប... ណាខ្មាសពិចិត្ត... ណាគ្រុនញាំញីលាយឡំគ្នាឥតបានសម្រាន្តលក់ រហូតទាល់តែដល់ភ្លឺ។ ប៉ុន្តែដោយសារឥទ្ធិពលថ្នាំពីរគ្រាប់ ដែលពិចិត្តឲ្យខ្ញុំលេបកាលពីយប់នោះ ទើបខ្ញុំក៏បានធូរស្រាល។

ភ្លឺឡើងពិចិត្តឲ្យខ្ញុំលេបពីរគ្រាប់ទៀត... ខ្ញុំក៏សម្រាន្តលក់រហូត។ ភ្ញាក់ឡើងខ្ញុំយកបាយកក និងបុកក្រសាំងដែលមីងម៉ៅបានឲ្យខ្ញុំកាលពីល្ងាចម្សិល ហុចឲ្យទៅពិចិត្ត។ ពិចិត្តទទួលយកចានបាយពីដៃខ្ញុំម្ខាង ឯដៃម្ខាងទៀតចាប់ដៃខ្ញុំ ហើយនិយាយបបួល ៖

- អូនហូបជាមួយបងណាំ... អូនឯងចិត្តល្អណាស់... បងអាណិតអូនខ្លោចចិត្ត។

ពាក្យពិចិត្តពីរបីឃ្លាខ្លីៗ ប៉ុន្តែមុតជ្រៅឆ្ពុះដួងចិត្តខ្ញុំ។ ខ្ញុំឥតនិយាយតប ក៏អង្គុយ





ក្បែរគេ... រួចខ្ញុំហូបបាយ។ ហូបបាយបណ្ដើរ ពិចិត្តញញឹមមើលមុខខ្ញុំបណ្ដើរ... ព្រមទាំងនិយាយកំប្លែងលេង ៖

- ព្រំដែនត្រូវបានរំសាយនៅយប់ទីពីរ...

ខ្ញុំរកនឹកឆ្លើយមិនទាន់ ក៏បែរជាដាក់កំហុសទៅលើគ្រុនទៅវិញ ៖

- ហ៊ឺស... ដោយសារតែគ្រុនទេ... កុំអី...

ពិចិត្តប្រញាប់បញ្ចប់ឃ្លាភ្លាម ៖

- កុំអីក៏បងមិនបានឱបអូនដែរ... មែនទេ?

ខ្ញុំទៅជានឹកហួសចិត្តនឹងពាក្យដែលពិចិត្តនិយាយ ៖

- យី! អូនបងអីក៏ដូចជារអិលម្ល៉េះ?

ហូបបាយហើយ ពិចិត្តក៏បង្ខំឲ្យខ្ញុំសំងំដេកទៀត។ ភ្ញាក់ឡើង ខ្ញុំឃើញក្រដាសមួយសន្លឹកនៅក្បែរសំពៀតដាក់ខោអាវខ្ញុំ ខ្ញុំក៏យកមកលាមើលឃើញសរសេរជាឃ្លាប្រយោគ ដែលថ្លែងពីសេចក្ដីស្នេហាផ្អែមល្ហែម ៖

" *អូន និង បង* "

I. បងនឹកស្រមៃនឹកដល់ស្រីថ្លៃ គ្មានថ្ងៃណារសាយទេ
បងនឹក អើយបងនឹក អនុស្សាស្នេហ៍ ដែលមាសមេបំពេថ្នាក់ថ្នម។

II. រស់ស្នេហ៍បរិសុទ្ធ ល្អបំផុត ទើបច្យុតិចុះមកប្រលោម
ព្រលឹងកំពូលដួងចិត្ត រៀមសូមបីបម លួងលោមឆោមដាក់លើឱរា។

III. ស្រអែមតូចតន់ សម្រស់ល្អគន់ មិនឆ្អន់ទ័យា
អូនឯងចម្លែក ខុសប្លែកស្រីនានា ក្នុងដែនរដ្ឋាកម្ររកពុំបានផង។

IV. ស្រីស្រស់សន្ទឹក តែបងមិននឹក ដូចរឮកនួនល្អង មានអ្វីសម្គាល់
គឺស្រអែមតូចថ្កាល់ខ្ចូចទាំងសង ដួងចិត្តបងចារឈ្មោះ អូនជាប់ជានិច្ច...។

ខ្ញុំនឹកស្ងួត... រំភើប... នឹងអត្ថន័យនៃសេចក្ដីកំណាព្យ ដែលពិចិត្តតែងជាប្រយោគឃ្លោងឃ្លាពីរោះរណ្ដំ... យី! ពិចិត្តជាអ្នកករនិពន្ធផង ខ្ញុំនឹកគិតថា អត្ថន័យនេះពិចិត្តតែងឲ្យនរណា ឬមួយក៏តែងឡើងដើម្បីឌឺដងក្នុងន័យស្នេហាចំពោះរូបខ្ញុំ បើប្រសិនណាគេតែងឡើងចំពោះរូបខ្ញុំមែន មានឃ្លាខ្លះដូចជាបញ្ឆោរខ្ញុំពេកហើយហើយ មានឃ្លាខ្លះទៀត ពិចិត្តបង្អាប់ខ្ញុំក៏ណាស់ដែរ ត្រង់ដែលថា ស្រីស្រស់សន្ទឹកតែបងមិននឹកដូចរឮកនួនល្អង។

ដូច្នេះ ឃ្លាត្រង់នេះបានន័យថា ខ្ញុំមិនស្អាតទេ ប៉ុន្តែធ្វើឲ្យគេរឮក។

ខ្ញុំអង្គុយស្មានតែម្នាក់ឯង រួចខ្ញុំអានអត្ថបទសាចុះសាឡើង ដែលអត្ថបទនេះមានតែបួនវគ្គប៉ុណ្ណោះ ប៉ុន្តែខ្ញុំអានមិនឆ្អែតសោះ... ឱ! អីក៏ពីរោះម្ល៉េះទេ ព្រះអើយ... ឬមួយក៏ខ្ញុំស្រឡាញ់កំណាព្យ ឬមួយក៏ខ្ញុំចាប់ផ្ដើមស្រឡាញ់ពិចិត្តម្ចាស់កំណាព្យ ឬមួយក៏របបគ្រោតគ្រាតនេះ ធ្វើឲ្យខ្ញុំស្រេកឃ្លានពាក្យផ្អែមល្ហែម លួងលោម ថ្នាក់ថ្នម?

ខ្ញុំចេះតែក្រឡេកមើលទៅមាត់ទ្វារជាញឹកញាប់ ទើបចិត្តមួយសួរខ្លួនឯងថា តើខ្ញុំមើលផ្លូវនរណា? ចុះក្រែងខ្ញុំមិនចូលចិត្តគេ... ស្អប់គេ... ឥឡូវខ្ញុំមើលផ្លូវគេធ្វើអ្វី?

ចិត្តវិភាគប្រឆាំងគ្នាចុះឡើងៗ ទើបឃើញពិចិត្តដើរចូលមក។ ខ្ញុំក៏ប្រញាប់បត់ក្រដាសដាក់ចំកន្លែងដដែលវិញ ធ្វើឫកដូចជាពុំទាន់បានមើលបានឃើញអ្វីចម្លែក។ ពិចិត្តញញឹមទាំងស្ងួតដាក់ខ្ញុំ រួចប្រញាប់ឡើងមកលើផ្ទះ ហើយចូលមកអង្គុយ





ជិតខ្ញុំ គេយកដៃមកស្ទាបថ្ងាសស្ទាបដៃខ្ញុំ រួចលាន់មាត់ ៖

- អូនបាត់ក្ដៅហើយ... អូនជាហើយឬ?

ខ្ញុំគ្រាន់តែឆ្លើយ ៖

- ចាស!

ខ្ញុំរង់ចាំសំណួរ... ប៉ុន្តែស្ងាត់ឈឹង... ខ្ញុំមើលទៅពិចិត្ត ខ្ញុំឃើញគេសម្លឹងចំមុខខ្ញុំឥតព្រិចសោះ។ ខ្ញុំភាន់ភាំង រួចបែរជានៅនឹងថ្កល់ស្រឡាំងកាំងនឹងក្រសែភ្នែករបស់គេ... ហើយហាក់ដូចជាមានអ្វីមកស្រូបឆក់ដោយកម្លាំងចរន្តអគ្គិសនី... រួចខ្ញុំខំប្រមូលថាមពលដែលមាននៅក្នុងខ្លួនដោយល្បឿយ គេចចេញពីទម្ងន់ខ្សែចក្ខុនេះ។

ខ្ញុំខំតាំងចិត្តឲ្យក្លាហាន ឲ្យដូចរាត្រីដំបូងដែលខ្ញុំហ៊ានជជែកត៉ាវ... ឆ្លងឆ្លើយដោយគំរោះគំរើយជាមួយគេ... មិនតែប៉ុណ្ណោះ ខ្ញុំថែមទាំងហ៊ានចូលទៅសម្រាកលើកន្ទេលស្លឹកត្នោតយ៉ាងព្រងើយ ជាមួយបុរសចម្លែកនេះទៀតផង... ប៉ុន្តែហេតុដូចម្ដេចក៏អ្វីៗឆាប់ប្រែប្រួលរហ័សម្ល៉េះហ្ន៎!

ខ្ញុំនឹកទៅរាត្រីទីពីរ ដែលគេស្រវាឱបខ្ញុំនៅក្នុងរង្វង់ដៃទាំងគូ... ថ្វីត្បិតតែខ្ញុំមានការលំបាកដោយក្ដីញាប់ញ័ររន្ធត់បន្តិចមែនក៏ដោយ... ក៏ប៉ុន្តែខ្ញុំដូចជាមានសេចក្ដីសុខដោយសារឥទ្ធិពលស្នេហ៍ ដែលព្រហ្មលិខិតប្រទានមួយភ្លែតដែរ។

ពិចិត្ត... ពិចិត្ត... ខ្ញុំលួចហៅឈ្មោះគេផ្ទួនៗច្រើនសាតែក្នុងចិត្តម្នាក់ឯង... មិនឮគេឆ្លើយតបវិញសោះ... ឱ! ខ្ញុំឆ្កួតហើយទេដឹង... ខ្ញុំហៅគេមិនឮសំឡេងផង តើឲ្យគេឆ្លើយតបមកខ្ញុំឮសំឡេងម្ដេចនឹងកើត? ខ្ញុំឆ្លៀតងាកទៅមើលមុខពិចិត្តសាជាថ្មីដែលទឹកមុននេះមានសភាពក្រៀមក្រំស្រពោនចម្លែក... ហើយសូម្បីខ្លួនខ្ញុំក៏មិនយល់ខ្លួនឯងដែរថា ពេលនោះស្រាប់តែខ្ញុំស្រយុតស្រយង់ នឹកអាណិតពិចិត្តខ្លោចចិត្ត

រួចកើតចិត្តចង់ជួយឈឺឆ្អាល... សួរនាំពីមូលហេតុដែលបណ្តាលឲ្យគេក្រៀមក្រំស្រពោន។

ខ្ញុំមិនទាន់ទាំងផ្តើមសួរផង... ស្រាប់តែខ្ញុំឮពិចិត្តនិយាយមុនខ្ញុំទៅហើយ ដោយសំឡេងតិចៗយ៉ាងស្រាល ៖

- យុន! អូនសម្លាញ់បង!

ពុទ្ធោអើយ មិនដឹងជាយ៉ាងដូចម្តេចទេ ស្រាប់តែខ្ញុំរលីងរលោងទឹកភ្នែក ហើយគេចមុខចេញយ៉ាងរហ័ស មិនហ៊ាននៅប្រឈមទទឹងនឹងនេត្រាដែលកំពុងតែសម្លឹងអង្វរករ។ ពិចិត្តបន្ថែមឃ្លាបន្ត ៖

- យុន... ស្រឡាញ់បងទេ?

ជាសំណួរដែលពិចិត្តជាតួឯកខាងប្រុស កំពុងឈានជើងចូលក្នុងឈុតស្នេហាបន្តិចម្តងៗ។

ទឹកភ្នែកខ្ញុំដែលរលីងរលោង ស្រាប់តែដណ្តើមចេញប្រជេញបន្តបន្ទាប់ជាប់ៗគ្នារដឹក។ ខ្ញុំមិនឮពិចិត្តនិយាយឃាត់ខ្ញុំមិនឲ្យយំទេ ប៉ុន្តែខ្ញុំបែរជាឃើញគេទាញក្រមាពីស្មាខ្ញុំ យកមកផ្តិតទឹកភ្នែកដែលហូរកាត់ថ្ពាល់ខ្ញុំទៅវិញ... ហើយខ្ញុំងាកមុខចេញពីដៃថ្នាក់ថ្នមរបស់គេទាំងទ្រូងអួលអាក់ ខ្ញុំហាមាត់ឆ្លើយមិនរួចសោះ... ខ្ញុំបាត់បង់សេចក្តីក្លាហានដែលខ្ញុំមានពីដំបូង។

ពិចិត្តសួរខ្ញុំលើកនេះ មិនមែនសួរក្នុងលក្ខណៈដោះទ័លដូចរាត្រីទីពីរទេ គឺគេសួរខ្ញុំមែនទែន ដោយចង់ចម្រាញ់យកចម្លើយពីបេះដូងបរិសុទ្ធរបស់ខ្ញុំ។ ខ្ញុំចេះតែនឹកឆ្ងល់នឹងអាកប្បកិរិយាពិចិត្ត ដែលខុសប្លែកពីពីរថ្ងៃដំបូង ម្យ៉ាងទៀត ទឹកមុខហ្នឹងមិនសមជាត្រូវមកសង្កួញសំណួរអ្វីរហ័សម្ល៉េះយ៉ាងនេះទេ... តើគេមានអាថ៌កំបាំង





អ្វីទៅ?

ឃើញខ្ញុំដូចជាមានឫកពាទន់ភ្លន់ច្រើន គេក៏លូកដៃមកកាន់ច្របាច់ដៃខ្ញុំថ្នមៗព្រមទាំងបន្លឺវាចារ៉ាយរ៉ាប់ ពីភារកិច្ចដែលត្រូវទៅបំពេញមិនអាចអាក់ខានបាន ៖

- ល្ងាចនេះ អង្គការចាត់ឲ្យបង និងមិត្តយើងប្រាំបួននាក់ទៀតចូលធ្វើទ័ព... ទៅការពារព្រំដែនខ្មែរ-យួន...

ពិចិត្តឈប់ដកដង្ហើមបន្តិច ទើបបន្តទៅទៀតរបៀបមនុស្សពុំមានទម្លាប់និយាយច្រើន។

...តាមទិសអង្គការថា ប្រហែលជាមានការវាយលុកយកកម្ពុជាក្រោមផង... អូនកុំមាត់ប្រាប់នរណាឲ្យសោះណា៎... នេះជារឿងលាក់ការណ៍។

ឮដំណឹងនេះភ្លាម ខ្ញុំងាកមុខមករកពិចិត្ត រួចស្រាប់តែនិយាយដោយមិនដឹងខ្លួន ៖

- ទេ! មិនឲ្យបងទៅណាចោលខ្ញុំទេ!

ពិចិត្តក្រសោបខ្ញុំក្នុងហត្ថាទាំងទ្វេ រួចនិយាយលួងលោម ៖

- អង្គការឲ្យបងទៅតែកន្លះខែទេ... មិនយូរប៉ុន្មាន បងគង់នឹងវិលមកជួបអូនវិញហើយ។

ស្ថិតក្នុងរង្វង់ដៃពិចិត្តដ៏សែនកក់ក្តៅ ហើយនៅពេលដែលដៃនេះរលាចេញពីប្រាណខ្ញុំ ខ្ញុំហាក់ដឹងថា ខ្ញុំរងាចំប្រប់... ហេងហាង... កណ្តាលវាលល្ហល្ហេវ... ល្វឹងល្វើយឥតកោះត្រើយ...។

ខ្ញុំឈរយំដោយឥតដឹងខ្លួន... ដូចជាមនុស្សឥតវិញ្ញាណ... ឈរភាំងតាមមើលដំណើរពិចិត្តដែលឃ្លាតទៅពេលសន្ធិប្រកាស។

## ៣. វង់ចាំជានិច្ច

ពេលប្ដេជ្ញាហើយ ខ្ញុំនិងនារីទាំងអស់បានមកធ្វើការងារក្នុងភូមិជាមួយនឹងនារីកសិករឯទៀត។ ខ្ញុំបានជួបមីងម៉ៅរាល់ពេល ទោះទៅធ្វើការក្ដី ទៅហូបបាយ ឬត្រឡប់មកវិញក្ដី តែងតែដើរជាមួយមីងម៉ៅជានិច្ច ព្រោះយើងមានផ្ទះនៅជិតគ្នា។ ថ្វីត្បិតតែអាយុយើងទាំងពីរខុសគ្នាឆ្ងាយក៏ដោយ ក៏មីងម៉ៅតែងតែសាទុក្ខសាទោសប្រាប់ខ្ញុំជានិច្ច... រហូតដល់ពេលខ្លះ ខ្ញុំលាន់មាត់និយាយនឹករឭកពិចិត្ត ប្រាប់ដល់មីងម៉ៅផងដែរ។ មីងពុំដែលរិះគន់ខ្ញុំទេ មានតែជួយណែនាំប្រាប់ពីរឿងរ៉ាវសំខាន់ៗទាំងឡាយ ឲ្យខ្ញុំប្រុងប្រយ័ត្នជានិច្ចទៀតផង។

នៅពេលដែលមីងម៉ៅនឹកដល់ប្ដីគាត់ម្ដងៗ គាត់និយាយរៀបរាប់ពីអតីតកាលប្រាប់ខ្ញុំ និងនិយាយពីលក្ខណៈស្ត្រីល្អ ត្រូវធ្វើយ៉ាងណាចំពោះប្ដី ដើម្បីឲ្យមានសុភមង្គល។ តាមសម្ដីរបស់មីងម៉ៅ ក្នុងគ្រួសារគាត់ល្អូកល្អើនណាស់ ប្រហែលជាមិនដែលមានឈ្លោះប្រកែកអ្វីធំដុំទេមើលទៅ។ មីងទន្ទឹងមើលផ្លូវប្ដី ឯខ្ញុំក៏ទន្ទឹងមើលផ្លូវពិចិត្តដែរ យើងមានទុក្ខប្រហែលគ្នា។ ខ្ញុំរាប់ដៃដូចកូនក្មេង ព្រោះយើងគ្មានវិទ្យុស្ដាប់ គ្មានប្រតិទិនមើល ហើយពុំដែលមានពត៌មានអ្វី ក្រៅពីសម្រុកធ្វើការងារលើកទំនប់ ជីកប្រឡាយ ដកស្ទូង ច្រូតកាត់ច្រំដែលៗ មួយថ្ងៃៗយូរអើយសែនយូរដូចមួយសតវត្ស។ មីងម៉ៅចូលចិត្តស្ដាប់ចម្រៀងណាស់ ពេលណាដើរស្ងាត់តែពីរ





នាក់ គាត់តែងតែបង្ខំឲ្យខ្ញុំច្រៀងកំដរគាត់ ខ្ញុំមិនដឹងជាមានសំឡេងពីរោះ ឬមួយក៏មិនពីរោះទេ ប៉ុន្តែសម្រាប់មីងម៉ៅ គាត់តែតែលាន់មាត់ថា ៖

- មីអូនឯងច្រៀងពីរោះណាស់... ពេលមីអូនច្រៀងម្ដងៗ មីងបានស្បើយពីទុក្ខសោកទាំងឡាយ។

ដោយសារខ្ញុំចេះច្រៀងលួងលោមមីងម៉ៅ ទើបគាត់បានចាត់ទុកខ្ញុំដូចជាក្មួយគាត់បង្កើត។ មីងម៉ៅប្រសប់ច្នៃប្រឌិតធ្វើម្ហូបណាស់ អ្វីៗក៏មីងម៉ៅចេះដែរ បើដល់ពេលរដូវវស្សា មីងម៉ៅសន្សំត្រីបានធ្វើផ្អក គាត់តែងតែផ្ដល់ម្ហូបអាហារបន្តិចបន្តួចដែលគាត់មាន មកឲ្យខ្ញុំដោយលួចលាក់។ អ្វីៗដែលមីងម៉ៅឲ្យខ្ញុំ មានរសជាតិឆ្ងាញ់ណាស់... ឬមួយក៏អត់បានជាឆ្ងាញ់ដូច្នេះ? មីងម៉ៅមិនហៅខ្ញុំចំឈ្មោះទេ គាត់ហៅខ្ញុំថា "មីអូនៗ" ប្រហែលជាគាត់ពេញចិត្តនឹងខ្ញុំខ្លាំងណាស់ ហើយមើលទៅបានជាហៅពាក្យទំយើយ៉ាងនេះ។

ថ្ងៃមួយ ខ្ញុំបានតែងចម្រៀងមួយបទមានចំណងជើងថា "ទារុណអមនុស្សធម៌" :

*" ទារុណអមនុស្សធម៌ "*

I- ចេញៗៗ ភ្នំពេញអើយ ខ្ញុំលាអ្នកហើយទុក្ខគ្មានស្បើយនៅក្នុងឱរា
ខ្ញុំដឹងថា យើងគ្មានសេរី តាំងពីចេញបានមួយថ្ងៃម្ល៉េះ។

II- ទប់ៗ លើកទំនប់ និងជីកប្រឡាយ សែនខ្វល់ខ្វាយហ្នឹងហើយចំណេះ
មហាវិទ្យាល័យនេះរៀនកាប់ រៀនរែក ចាំបាច់អ្វីរៀនក្នុងសាលា។

បន្ទរ - ខ្ញុំឈរ... លើស្រែគំរូឲ្យអារម្មណ៍ធូរពីទុក្ខសោកា ផ្ទុយទៅវិញ
ខ្ញុំសែនខ្លោចផ្សា ព្រោះព្រាត់មាតាបិតា និងញាតកាផងទាំងឡាយ។

III- ស្មើៗ សហករណ៍ផ្ញើ ប្រុងចិត្តប្រុងកាយ បើបាត់ខ្លួនកុំបីឆ្ងល់ឆ្ងាយ
មុខជាអន្តរាយកាយសូន្យសង្ខារ... អនិច្ចាវាសនាខ្មែរអើយ។

ចម្រៀងនេះ ខ្ញុំបានច្រៀងឲ្យមីងម៉ៅស្ដាប់មុនគេ។ មីងម៉ៅកាន់តែស្រឡាញ់ខ្ញុំថែមទៀត ព្រោះខ្ញុំចេះតែងដោយខ្លួនឯង។

គាត់សួរខ្ញុំ ៖

- មីអូនឯងជាអ្នកចម្រៀងឬ?

ខ្ញុំឆ្លើយ ៖

- ទេមីង!

មីងម៉ៅនៅតែឆ្ងល់ ហើយសួរថែមទៀត ៖

- ដូចម្ដេចក៏ឯងចេះតែងបាន?

ខ្ញុំបកស្រាយ ៖

- ខ្ញុំស្រឡាញ់ចម្រៀងខ្លាំងពេក ក៏ចេះច្រៀងចេះតែងតែម្ដងទៅ។

មីងម៉ៅមិនយល់ស្របតាមគំនិតខ្ញុំ ក៏ឆ្លើយប្រឆាំង ៖

- ចុះមីងស្រឡាញ់ចម្រៀងខ្លាំងដែរ ហេតុដូចម្ដេចក៏មិនចេះច្រៀងមិនចេះតែង?

ខ្ញុំប្រញាប់និយាយយកឈ្នះ ៖

- ព្រោះមីងមិនព្រមច្រៀង មិនព្រមតែងហ្នឹងណា។

មីងម៉ៅនៅតែប្រកែក ៖

- ច្រៀងយ៉ាងម៉េច បើសំឡេងមិនបាន... តែងយ៉ាងម៉េច បើមិនចេះអក្សរភ្លេង!

ខ្ញុំតបភ្លាមដោយឥតព្រាងទុកឡើយ ៖





- ច្រៀងមិនចាំបាច់សំឡេងបានទេ... តែងក៏មិនចាំបាច់ចេះអក្សរភ្លេងដែរ ដូចយ៉ាងខ្ញុំមានសំឡេងពីរោះដូចអ្នកចម្រៀងល្បីឯណា ម៉េចក៏ខ្ញុំច្រៀងបាន ហើយចម្រៀងវិញ ខ្ញុំក៏អាចតែងបានទៀត តើខ្ញុំមានចេះអក្សរភ្លេងឯណា? ប៉ុន្តែមនោសញ្ចេតនាខ្ញុំវាពុះពោរខ្លាំងពេក វារំភើបពេក ទើបធ្វើឲ្យខ្ញុំតែងបានដូច្នេះឯង។

មីងម៉ៅឆ្លើយតប ៖

- មីអូននិយាយយ៉ាងនេះ មីងស្របហើយ តែទាល់តែវាមានទេពកោសល្យផងដែរ បើគ្រាន់តែស្រឡាញ់ដូចមីង ហើយគ្មានទេពកោសល្យផងនោះទេ នៅតែទៅមិនរួចរហូតអីចឹង។

ខ្ញុំងក់ក្បាលយល់ព្រមតាមគំនិតចុងក្រោយរបស់មីងម៉ៅ។ មីងម៉ៅលួចនិយាយខ្សឹបៗដាក់ត្រចៀកខ្ញុំ ៖

- បទសព្វថ្ងៃ មីងស្ដាប់មិនចូលទេ ឮម្ដងៗដូចជាចង់ស្ទះដាច់ដង្ហើម។

ខ្ញុំនិយាយផ្ទាន់ដោយក្ដីស្រឡាញ់ ៖

- ចុះក្រែងមីងស្រឡាញ់ចម្រៀងឬ?

មីងឆ្លើយរបៀបរំភើបញ្ញែក ៖

- មីងស្រឡាញ់ចម្រៀងមែន តែមិនមែនចម្រៀងរបៀបរោងចក្រអីចឹងទេ ព្រោះពាក្យចម្រៀង គឺជាពាក្យថ្នមលួងលោមឲ្យទុក្ខសោកទាំងឡាយបានរសាយ ចុះបើស្ដាប់ចម្រៀងរបបនេះ មីងតានតឹងក្នុងចិត្តដដែល តើមានប្រយោជន៍អីនឹងស្ដាប់នោះ! មីអូនឯងមានចាប់អារម្មណ៍ទេ! កាលពីទើបរំដោះថ្មីៗគេចាក់បទក្រុត ប៉ុន្តែគេតែងខ្លឹមសារបដិវត្តរបស់គេ មីងស្ដាប់ទៅដូចជាសម្រែកខ្មោចទារព្រលឹង...

ខ្ញុំឆ្លើយកាត់ ៖

ភូមិត្រពាំងត្នោត... ត្រពាំងគល់... ត្រពាំងកោះ... ត្រពាំងរំដេញ... ត្រពាំងស្លាត់... ត្រពាំងជម្រៅ... ត្រពាំងធំ ។ល។ ដូច្នេះ មីងម៉ៅគាត់ក៏នឹកភ្នកដល់រឿង "ត្រពាំងបិសាច" ហើយសំណូមពរឲ្យខ្ញុំនិទានឲ្យគាត់ស្តាប់។ រឿងត្រពាំងបិសាចនោះ ខ្ញុំធ្លាប់បានរៀន កាលខ្ញុំនៅថ្នាក់ទីបី នៅវិទ្យាល័យដប់ប្រាំបីមីនា (អតីតវិទ្យាល័យព្រះយុគន្ធរ បច្ចុប្បន្នជាសាលាបំពេញវិជ្ជាមជ្ឈិម) កាលនោះខ្ញុំរៀនជាភាសាបារាំង លុះដល់ខ្ញុំនិយាយចប់ មីងម៉ៅគាត់ឲ្យខ្ញុំបញ្ជាក់សាឡើងវិញ នូវកន្លែងខ្លះដែលគាត់ពេញចិត្តពេក ឬមួយក៏កន្លែងខ្លះគាត់ស្តាប់មិនច្បាស់ក៏មិនដឹង។ ខ្ញុំនិយាយ ៖

- អ្នកនិពន្ធ ហ្សកសង់ បានសរសេររឿង "ត្រពាំងបិសាច" នេះ ទុកជាស្នាដៃបង្ហាញឲ្យជនជាតិរបស់គាត់ និងជនជាតិទាំងអស់លើសាកលលោក ក្រេបជញ្ជក់រសជាតិខ្លឹមសារនេះ ទុកជាទុនសម្រាប់ការតែងនិពន្ធ។

ត្រពាំងបិសាច... អ្នកនិពន្ធបានចាប់ផ្តើមតែងរឿងឡើងនៅល្ងាចថ្ងៃសៅរ៍... រួចបញ្ចប់រឿងនៅល្ងាចថ្ងៃអាទិត្យ... គឺពិតជាជីវិតសាមញ្ញមួយនៅជនបទនៃត្រកូលកសិករគ្រាន់បើមួយ និងត្រកូលទុគ៌តមួយ... រួចទីបំផុត អ្នកនិពន្ធនេះបានផ្សំផ្គុំត្រកូលទាំងពីរ... ហើយក៏បញ្ចប់សាច់រឿងជាស្ថាពរ... ធ្វើឲ្យខ្ញុំអ្នកនិយាយៗហើយនិយាយទៀត ទាល់តែមីងម៉ៅម្តងនឹកស្រឡាញ់ត្រង់ ហ្សែកម៉ាំង បន្ថែមអុសឲ្យភ្លឺឡើង ដើម្បីកម្តៅខ្លួននាងម៉ារី និងពីទីតព្យែរ ដែលកំពុងលង់លក់ក្នុងទ្រូងព្រៃជ្រៅចុះអ័ព្ទក្បែរត្រពាំងបិសាច... ម្តងនឹកស្រឡាញ់ត្រង់នាងម៉ារីយំ ពេលដែលហ្សែកម៉ាំងឲ្យលុយទៅម្ចាស់ភោជនីយដ្ឋាននៅជនបទមួយ រួចនិយាយបង្ហាញនាងម៉ារីធ្វើឲ្យនាងនឹកឃើញម្តាយចាស់កម្សត់ ក្នុងរដូវធ្លាក់ទឹកកកនាពេលខាងមុខនេះ...។

មីងម៉ៅស្លុងគំនិតទៅលើសាច់រឿង... រួចផ្ទុះសម្តីឡើងថា ៖





- ឱ! ប្រទេសដទៃលើសកលលោកអើយ... ចុះមានប្រទេសណាដូចប្រទេសខ្ញុំដែលខ្ញុំកំពុងរស់នៅនេះទេ អីក៏ចម្លែកជាងគេម្ល៉េះ... គ្មានសិទ្ធិ... គ្មានសេរី... វាស់ផ្លូវឲ្យដើរ... កាត់ផ្តាច់មនោសញ្ចេតនារវាងម៉ែឪ... បងប្អូន... សាច់ញាតិ... ហើយអ្វីៗហាក់ដូចជាហ៊ុមព័ទ្ធដោយស្បៃអពមង្គល... ឲ្យតានតឹងសឹងតែបែកទ្រូងស្លាប់។

## ៤. ការកិច្ចថ្មី

ថ្ងៃមួយ ពេលខ្ញុំកំពុងច្រូតកាត់ មិត្តខ្ញុំម្នាក់និយាយប្រាប់ខ្ញុំថា បងស្រីខ្ញុំស្លាប់ហើយ ខ្ញុំស្លុតខ្លាំងពេក ផ្រុលកណ្ដៀវមកត្រូវដៃមុតចេញឈាម ដូចគេអារកមាន់ នឹកឃើញដល់ពិចិត្តយកស្មៅចិញ្ចៀនមកទំពាបិទ ខ្ញុំក៏ធ្វើតាម។ ខ្ញុំស្រក់ទឹកភ្នែក... គេទាំងអស់គ្នានឹកស្មានតែខ្ញុំយំនឹងការឈឺចុកចាប់នឹងកណ្ដៀវមុតដៃ... ប៉ុន្តែការពិតខ្ញុំយំនឹករឭកបងស្រីសម្លាញ់ ដែលបានចែកឋានទៅយ៉ាងកម្សត់តែម្នាក់ឯងលើគ្រែស្មោកគ្រោកមួយដែលខ្ញុំធ្លាប់បានឃើញរួចមកហើយ ហើយខ្ញុំនឹកទៀតថា ពួកវាគ្មានទៅមុជទឹក... សម្អាតខ្លួនឲ្យបងខ្ញុំ នាថ្ងៃចុងបញ្ចប់នេះទេ... រួចបងស្រីខ្ញុំនឹងសម្រាន្តយ៉ាងយូរ... រហូតក្នុងព្រះធរណីគ្មានពេលនឹងត្រឡប់មកជួបខ្ញុំវិញបានឡើយ។ នៅថ្ងៃចុងក្រោយបំផុតនោះ ពួកវាមិនឲ្យដំណឹងមកខ្ញុំដឹងសោះ... ទោះជាខ្ញុំមានបងប្អូនតែពីរនាក់ក៏ដោយ។ ទឹកភ្នែកសើមជោកជាយក្រមា... ខ្ញុំងើបឡើងធ្វើការងារបន្ត ប៉ុន្តែអារម្មណ៍ខ្ញុំបានរំឭកនូវអតីតអនុស្សាវរីយ៍ទាំងឡាយរវាងបងនិងខ្ញុំ។

កាលយើងនៅពីក្មេង គាត់ចូលចិត្តខោកក្បាលខ្ញុំណាស់... ហើយកាលណាមានរឿងអាក់អន់ចិត្តអ្វីមួយ គាត់ឈប់និយាយរកខ្ញុំភ្លាម បើខ្ញុំចង់និយាយរកគាត់ ខ្ញុំតែងតែសូកគាត់ គឺខ្ញុំសូកគាត់ជានំចំណី ឬជាស្ករគ្រាប់។ ហេតុដែលបណ្ដាលឲ្យ





ខ្ញុំខំយកចិត្តគាត់ដូច្នេះ ព្រោះបងខ្ញុំពូកែនិយាយរឿងឲ្យខ្ញុំស្ដាប់ណាស់។ បើគ្មានរឿងនិយាយទេ គាត់ប្រឌិត... ហើយរឿងដែលគាត់និយាយនោះ ស្ដាប់ទៅពីរោះណាស់... មានជួនកាលគាត់ប្រឌិតពុំទាន់ ខ្ញុំក៏សំណូមពរឲ្យគាត់និយាយសាឡើងវិញ នូវរឿងណាដែលខ្ញុំយល់ថាពីរោះ ឬក៏កំប្លែងជាងគេ។ នឹកដល់ថ្ងៃចុងក្រោយបំផុតដែលខ្ញុំបានដេកជាមួយបងស្រីមួយយប់ នៅមន្ទីរពេទ្យស្រុក។ បងខ្ញុំគាត់ឃ្លានចំណីចំណុកខ្លាំងពេក ក៏ឲ្យខ្ញុំរៀបចំអាហារខ្លះដែលគាត់ចូលចិត្ត តាមរយៈការនិយាយរៀបរាប់។ តាមពិតខ្ញុំមិនចំណាប់ខាងការធ្វើម្ហូបទេ កាលនៅជាមួយឪពុកម្ដាយ ខ្ញុំបានធ្វើម្ហូបតែពីរដងគត់... ថែមទាំងពុំត្រូវមាត់លោកឪពុកខ្ញុំផង... តែពេលនេះ ការធ្វើម្ហូបអាហារតាមពាក្យសម្ដីនិយាយរៀបរាប់ វាមានទៅពិបាកអី... ហើយម្ហូបមួយមុខៗ ខ្ញុំរៀបចំតែប្រាំនាទី។ មានម្ហូបខ្លះ ខ្ញុំភ្លេចទាំងនិយាយថា ដាក់ម្សៅស៊ុប (ប៊ីចេង) ទៀតផង ប៉ុន្តែការនិយាយប្រឌិតរបស់ខ្ញុំ ធ្វើឲ្យបងស្រីខ្ញុំឃ្លាន... ចេះតែឆ្ងាញ់ហើយ... នៅទីបំផុត គាត់លេបទឹកមាត់... គាត់ផ្អែតតែទឹកមាត់ពេញពោះ ឱ! ពុទ្ធោអើយ យើងមានម្ហូបអាហារឯណា?

ខ្ញុំរំឭកដល់ត្រង់នេះ ទឹកភ្នែកដណ្ដើមគ្នាហូរ ធ្វើឲ្យរំខានដល់ការងារ។ ខ្ញុំច្រូតយឺតណាស់ ព្រោះរវល់តែសោយសោកា។ ចំណែកមិត្តខ្ញុំចេះតែជួយច្រូតយកមុខខ្ញុំដើម្បីឲ្យទាន់គេ... រួចនិយាយលួងលោមខ្ញុំកុំឲ្យខ្ញុំយំខ្លាំងពេក ត្បិតពួកអាបិសាចនេះ វាតាមដានតាំងពីរឿងកំប៉ិកកំប៉ុកឡើងទៅ ដើម្បីយកទោសសម្លាប់ឲ្យអស់គ្មានសល់។

ខ្ញុំស្រាលខ្លួនដូចដុំសំឡីរសាត់តាមខ្យល់... បែកម៉ែ... បែកឪ... បែកបង... បែកប្អូន... បែកពិចិត្តគូស្រករថ្មី ឥឡូវបែកបងស្រីបង្កើតទៀត ខ្ញុំរស់តែម្នាក់ឯង មើល

ឃើញជីវិតឥតន័យ ឥតខ្លឹមសារអ្វីបន្តិចសោះ។

ខ្ញុំដើរមកផ្ទះទាំងទឹកភ្នែកហូរសស្រាក់...។

នឹកដល់ខ្លួនបែកបងប្អូន... នឹកដល់រូបបងស្រីដែលឋិតនៅក្នុងអារម្មណ៍ ហាក់ដូចជានៅថ្មីៗពេក ធ្វើឲ្យខ្ញុំនឹកស្រណោះ ហូរទឹកភ្នែកដោយឥតដឹងខ្លួន។

- សមមិត្តនារីមិនស្រួលខ្លួនឬ?

ខ្ញុំភ្ញាក់ព្រើតនឹងសម្តីប្រុសសួរ ធ្វើឲ្យអារម្មណ៍ដែលកំពុងរាយមាយក្នុងស្រមោលអតីតកាល វិលមកសណ្ឋិតក្នុងខ្លួនវិញ គឺសមមិត្តប្រធានក្រុម ដែលអង្គុយនៅបាំងខាងមុខក្បែរអ្នកបើកបរ គាត់ងាកមករកខ្ញុំ ដែលអង្គុយនៅបាំងខាងក្រោយ។ ខ្ញុំខំប្រឹងញញឹមទាំងទឹកភ្នែកទៅរកសមមិត្តប្រធាន ហើយឆ្លើយតបដោយសម្តីទន់ភ្លន់ ៖

- ចាស! ខ្យល់បក់មកខ្លាំងពេក សំរាមចូលភ្នែកខ្ញុំ។

សមមិត្តប្រធានញញឹមងក់ក្បាល រួចបែរមុខទៅមុខវិញ។ សមាជិកដែលចុះទៅមូលដ្ឋានលើកនេះ មានចំនួនដប់មួយនាក់។ ប្រុសមានចំនួនដប់នាក់ ស្រីមានចំនួនមួយនាក់។ កម្មាភិបាលទាំងដប់មួយរូបនេះមានភារកិច្ចទៅពង្រឹងឃុំដា និងឃុំទ្រៀក ដែលស្ថិតនៅក្នុងស្រុកមេម៉ត់ ខេត្តកំពង់ចាម នាឆ្នាំ១៩៨៣។

ដល់កំពង់ចម្លងព្រែកក្តាមហើយ។ ខ្ញុំចុះពីរថយន្តពណ៌បៃតងក្រមៅចំណុះមួយតោន ដើរមើលទិដ្ឋភាពកំពង់ចម្លងក្រោយថ្ងៃរំដោះ។ ថ្វីត្បិតតែសំណង់ចាស់ត្រូវខ្ទេចខ្ទីអស់គ្មានសល់ ដោយសារពួកឃាតករក៏ដោយ ក៏សំណង់ថ្មីៗធ្វើពីឈើប្រក់ក្បឿងមួយចំនួន ត្រូវបានកសាងឡើងដោយសមរម្យ និងមានលក្ខណៈជាសំណង់ប្រពៃណីជាតិ។ សំណង់ខ្លះជាភោជនីយដ្ឋានបានបើកទ្វារចំហ រង់ចាំទទួលអ្នកដំណើរផងទាំងឡាយ គ្រប់ស្រទាប់វណ្ណៈ គ្រប់សញ្ជាតិ ក្នុងគោលបំណងតែមួយ





គឺបំបាត់ការស្រេកឃ្លាន។ ខ្ញុំឃើញចុងភៅនៅខាងក្រៅ កំពុងចិញ្ច្រាំសាច់យ៉ាងញាប់ដៃ រួចបើកគម្របឆ្នាំងធំមួយ ដែលមានផ្សែងហុយទ្រលោមអណ្តែតថ្ពោលៗចេញពីឆ្នាំង ហាក់ដូចជាថប់នឹងការដែលគេខ្ទប់មកជាយូរ។ គាត់បង់សាច់គុយទាវមួយក្តាប់ដៃទៅក្នុងកន្ត្រងសំណាញ់មួយ ហើយជ្រលក់លើកៗកន្ត្រងនោះទៅក្នុងទឹកពុះបួនប្រាំដង ទំនងជាចង់ឲ្យសាច់គុយទាវឆាប់ឆ្អិន ទីបំផុតគាត់ក៏យកគុយទាវស្រុសនោះទៅដាក់ក្នុងចាន ដែលមានសាច់ចិញ្ច្រាំជ្រំទឹកស៊ុបទុកត្រៀមពីរបីនាទីមុន រួចហើយក៏ដួសទឹកស៊ុបពីរបីវែកតូចៗដាក់បន្ថែមជាការស្រេច។ បន្ទាប់មកមានអ្នកបម្រើលើកយកទៅជូនភ្ញៀវ ដែលអង្គុយរង់ចាំឯតុខាងក្នុង។

ការរៀបចំចម្អិនអាហារមួយចានម្តងៗ ទំនងដូចជាឆ្ងាញ់ពិតប្រាកដមែន ប៉ុន្តែខ្ញុំឥតស្រក់ទឹកមាត់សោះ ព្រោះរយៈពេលបួនឆ្នាំនេះ ជីវជាតិទាំងឡាយមានសល់កល់នៅក្នុងខ្លួនខ្ញុំគ្រប់គ្រាន់ ល្មមមិនស្រេកឃ្លានខ្លាំងពេក ដូចសម័យប្រល័យពូជសាសន៍ខ្មៅងងឹតនោះទេ។ អ្នកលក់... អ្នកទិញ... អ្នកដំណើរគគ្រឹកគគ្រេងចុះឡើងទៅមកហូរហែ និយាយសើចលេងក្អាកក្អាយសប្បាយរីករាយ។

កាលណាសាឡាងពីត្រើយម្ខាងចូលមកចតនៅកំពង់ផែ... ឡាន និងអ្នកដំណើរទាំងឡាយនាំគ្នាឡើងរសឹបរសាវយ៉ាងប្រញាប់ប្រញាល់ ដើម្បីឲ្យអ្នកដំណើរដែលនៅរង់ចាំឯត្រើយម្ខាង បានចុះឆ្លងទៅត្រើយម្ខាងទៀតផង។ ហើយសកម្មភាពឆ្លងទៅមកនេះចេះតែប្រព្រឹត្តចុះឡើងៗដូច្នេះ រហូតទាល់តែដល់ពេលល្ងាច ទើបឈប់តាមម៉ោងកំណត់។

យើងមកដល់ខេត្តកំពង់ចាម នៅវេលាម៉ោងប្រាំរសៀល។ ខ្ញុំចុះទៅមុជទឹកទន្លេនៅច្រាំងមុខវត្តដីដុះ មាត់ច្រាំងមានដុំថ្មរដិបរដុបគួរជាទីសប្បាយក្រៃលែង។

ប្រទេសបានសន្តិភាពហើយ... ប៉ុន្តែគូស្នេហ៍ខ្ញុំអើយ អ្នកនៅទីណា ខ្ញុំគ្រាន់តែដឹងថា ពិចិត្តចូលជាកងទ័ព ប៉ុល ពត អ្នកស្លាប់ក្នុងពេលប្រយុទ្ធហើយឬ... ឬមួយក៏អ្នករសាត់ចេញពីមាតុភូមិ ដោយកងកម្លាំងប្រដាប់អាវុធវៀតណាម រួមសហការជាមួយកងកម្លាំងប្រដាប់អាវុធកម្ពុជា ដេញអ្នកប៉ឹងខ្ចាត់ខ្ចាយបាត់ទៅហើយ?

ខ្ញុំរង់ចាំពិចិត្តផ្សាភ្នែក... ប៉ុន្តែស្ងាត់ឈឹង... ម្តងៗខ្ញុំគិតថា ពិចិត្តជាបុរសម្នាក់ដែលខ្ញុំពុំដែលស្គាល់ទាល់តែសោះ ហើយបានស្គាល់នៅពេលដែលរបបព្រៃផ្សៃរៀបចំប្តេជ្ញាឲ្យ។ តើបុរសហ្នឹងមានអ្វីជាសំខាន់សម្រាប់រូបខ្ញុំ... គួរតែខ្ញុំបំភ្លេចទៅ... ប៉ុន្តែហេតុអីក៏ខ្ញុំនឹកពិចិត្តឥតភ្លេចសោះយ៉ាងនេះ? មីងម៉ៅធ្លាប់និយាយថា បន្តិចទៀត មីអូននឹងនឹកគេ... ហើយរង់ចាំមើលផ្លូវគេ... ឥឡូវមែនហើយ មីងម៉ៅអើយ ខ្ញុំរង់ចាំគេមែន... រួចបើនិយាយពីការជួបគ្នាវិញ គឺយើងបានជួបគ្នាខ្លីណាស់ តែពីរថ្ងៃពីរយប់សោះ។

ទឹកទន្លេនៅរដូវក្តៅមានពណ៌ខៀវថ្លា ហូរវិញៗនាំសំណាត់ឈើតូចធំទាំងឡាយឲ្យអណ្តែតត្រសែតឥតទីដៅឆ្ងាយទៅៗ ហាក់បីដូចជារូបខ្ញុំ ដែលមានតែម្នាក់ឯងគត់នៅក្រោយថ្ងៃរំដោះ។ ចិត្តមួយបានកម្លាឲ្យខ្ញុំមានគោលជំហររឹងប៉ឹងឡើងវិញ ថ្វីត្បិតតែសាច់សាលោហិតផ្ទាល់របស់ខ្ញុំ ត្រូវបនក្បត់ប្រហារអស់គ្មានសល់ក៏ដោយ ក៏ជនដទៃទៀតដែលនៅរស់ អ្នកទាំងនោះជាញាតិមិត្តរបស់ខ្ញុំដែរ ព្រោះយើងបានស្គាល់ជីវិតជូរចត់ និងរួមទទួលវេទនាជាមួយគ្នា។ មិត្តទាំងឡាយនោះតែងតែជួយរំលែកទុក្ខធុរៈខ្ញុំគ្រប់ពេលវេលា ចំណែករដ្ឋអំណាចវិញ ក៏ជួយផ្គត់ផ្គង់ដល់រូបខ្ញុំ និងអ្នកដទៃទៀតជាច្រើនដែរ។ តើមានអ្វីឲ្យប្រសើរជាងនេះទៀត ចំពោះរូបខ្ញុំដែលបានស្គាល់រសជាតិល្វីងជូរចត់នៃនរកលោកិយ កាលពីសម័យប្រល័យពូជសាសន៍រួច





មកហើយ ខ្ញុំឥតត្រូវការអ្វីក្រៅពីសេរីភាព និងសន្តិភាពឡើយ។

ដោយសាររដូវនេះជារដូវក្តៅ ម្ល៉ោះហើយការមុជទឹករបស់ខ្ញុំបានប្រព្រឹត្តទៅយ៉ាងយូរ។ យើងសម្រាកនៅខេត្តមួយយប់ លុះស្អែកឡើង ទើបយើងធ្វើដំណើរឆ្ពោះទៅស្រុកមេមត់។ តាមផ្លូវជាតិ យើងសង្កេតឃើញប្រជាជនយកចិត្តទុកដាក់សង់លំនៅឋានណាស់ លក្ខណៈត្រង់នេះហើយ ធ្វើឲ្យខ្ញុំយល់ថា អ្នកស្រុកមានជំនឿទុកចិត្តលើបក្ស និងរដ្ឋ ព្រោះការសង់ផ្ទះមិនមែនជារឿងធម្មតាទេ ប្រសិនបើគេមិនជឿទុកចិត្តលើបក្ស និងរដ្ឋទេ តើគេចាំបាច់អ្វីនឹងខិតខំសាងសង់ផ្ទះ នាំឲ្យបង់ខាតប្រាក់កាសទ្រព្យសម្បត្តិឥតអំពើ? ហេតុដូចម្តេចក៏គេមិនដូរជាមាសប្រាក់ទុកទៅ គ្រាន់ងាយស្រួលដាក់តាមខ្លួន ប្រសិនបើមានការជន្លៀស ឬមានអសន្តិសុខកើតឡើងដោយប្រការណាមួយជាយថាហេតុ? ដូច្នេះ តាមសេចក្តីសន្និដ្ឋានរបស់ខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា ប្រជាជនមួយចំនួនធំ ក្នុងនោះរួមមានរូបខ្ញុំម្នាក់ទៀតដែរ គឺយើងរស់ដោយសប្បាយរីករាយ ទូលាយចិត្តថ្លើម មិនចង្អៀតចង្អល់។ ពីខេត្តកំពង់ចាមមកស្រុកមេមត់ មានចម្ងាយជិតកៅសិបគីឡូម៉ែត្រ (៩០ គ.ម.) យើងត្រូវធ្វើដំណើរឆ្លងកាត់ទិដ្ឋភាពដ៏ស្រស់បំព្រងនៃតំបន់ចម្ការកៅស៊ូ ដែលជាមូលដ្ឋានសេដ្ឋកិច្ចចម្បងនៃប្រទេសជាតិ។ ដីពណ៌ក្រហមដែលជាដីមាស មានជីវជាតិផ្តល់នូវថាមពលដ៏រកៅស៊ូឲ្យគុណភាពលេខមួយ។ ដើមកៅស៊ូដុះត្រង់ៗមានស្លឹកកញ្ចុំខាងលើ ឯដើមស្រឡះផេង គេដាំមានជួរមានបន្ទាត់ មើលទៅឃើញដើមដុះរត់ត្រង់ជួរភ្លឹងល្អណាស់។ បើដើរខាងក្រោមដើមវិញ ស្លឹកវាបាំងពន្លឺព្រះអាទិត្យ មិនធ្វើឲ្យយើងក្តៅទេ តែបើមើលពីចម្ងាយ យើងឃើញទិដ្ឋភាពនេះដូចជាខ្សែភ្នំដ៏វែង។ នៅលើទួល អ្នកស្រុកដាំស្រូវ (ការដាំស្រូវនេះ គេដាំនៅរដូវវស្សា) ដាំដំណាំរួមផ្សំ

ដាំកាហ្វេ ដាំធូរេន សាវម៉ាវ ខ្នុរ ចេក ស្មេកស្មុះ សបញ្ជាក់ឲ្យដឹងថា ជីវភាពអ្នកស្រុកសម្បូរធូរធារដែរ។

ដល់ស្រុកមេមត់ហើយ ដំបូងយើងត្រូវទៅបង្ហាញខ្លួននៅមន្ទីរស្រុកសិន ទើបបានស្រុកចាត់ឲ្យមកឃុំ។ មន្ទីរស្រុកនេះ តាំងនៅក្បែរចម្ការកៅស៊ូ។ ខ្ញុំមិនដែលស្គាល់ស្រុកមេមត់សោះ នេះជាលើកទីមួយហើយដែលខ្ញុំមកជាន់ទឹកដីស្រុកមេមត់នៅរបបថ្មី ហើយមានតួនាទីសមាជិកមកជួយពង្រឹងថ្នាក់ឃុំចំនួនបីខែ ផ្នែកខាងចលនាការងារនារី។ សមមិត្តប្រធានមានប្រសាសន៍ ៖

- តើក្រសួងរបស់សមមិត្តនារី ប្រហែលជាគ្មានមនុស្សធំមាំទេឬ បានជាចាត់ "កុមារី" ដូច្នេះ ?

ការពិតខ្ញុំមានអាយុច្រើនហើយ ប៉ុន្តែដោយសារខ្ញុំជាកូនកើតមកមិនគ្រប់ខែដូចអស់ទាំងគេ ទើបបានជាបណ្តាលឲ្យខ្ញុំមានរូបរាងតូចល្អិតយ៉ាងនេះ។ ខ្ញុំឥតខឹងទេ... ខ្ញុំនៅតែស្ងៀមមិនហ៊ាននិយាយតនឹងប្រធាន គ្រាន់តែនឹកថា តាមខ្ញុំស្មានមិនដឹងជាសមមិត្តប្រធានខ្វល់យ៉ាងណា... ព្រួយយ៉ាងណាក្នុងការចុះមកបំពេញភារកិច្ចនេះ ឬមួយក៏សមមិត្តប្រធានភ័យខ្លាចសមាជិកទាំងអស់គ្មានសំនួនវោហារដូចសមមិត្ត... ឬមួយក៏សមមិត្តខ្លាចចុះមកបំពេញភារកិច្ចមិនបានល្អ បានជាហែមកចាប់កំហុសពីមាឌតូចរបស់ខ្ញុំយ៉ាងដូច្នេះទៅវិញ។

យើងធ្វើដំណើរពីស្រុកមេមត់មកដល់ឃុំដា។ សមមិត្តប្រធានឃុំបានរៀបចំផ្ទះរបស់សមមិត្តផ្ទាល់ឲ្យខាងប្រុសៗ ចំណែកឯខ្ញុំ សមមិត្តបានប្រគល់ផ្ទះតូចមួយដែលនៅក្បែរខាងគ្នាឲ្យស្នាក់នៅ។

នៅពេលយប់ មានការបើកសម័យប្រជុំមួយ រវាងកម្មាភិបាលចុះពីមជ្ឈិម និង





ប្រជាជនមូលដ្ឋាន។ ហេតុអ្វីបានជាសមមិត្តប្រធានជ្រើសរើសយកពេលយប់មកប្រជុំ ? ព្រោះសមមិត្តចង់ឲ្យបានចំណេញពេល និងមិនចង់ឲ្យមានការប៉ះពាល់ការប្រកបការងាររបស់ប្រជាជន។ ខ្លឹមសារដែលសមមិត្តប្រធានលើកឡើង គឺចង់សង្កត់ធ្ងន់ទៅលើរបបថ្មី ជារបបដែលបក្ស និងរដ្ឋយកចិត្តទុកដាក់ដល់ជីវភាពប្រជាជន ... ផ្តល់នូវសិទ្ធិសេរីក្នុងការនិយាយស្តី... ដើរហើរ... ហូបចុក... ជាពិសេស ជ្រើសរើសគូស្រករ... ការរក្សាទុកប្រពៃណីទំនៀមទម្លាប់ជាតិ និងមានសិទ្ធិ មានជំនឿលើសាសនាណាមួយដែលខ្លួនប្រាថ្នា។ ថ្វីត្បិតតែខ្ញុំជាកម្មាភិបាលធ្លាប់បានត្រេបជញ្ជក់រសខ្លឹមសារនៃទ្រឹស្តីបែបនេះជាញឹកញយដង នៅរដ្ឋធានីក៏ដោយ ក៏ពេលនេះខ្ញុំអង្គុយស្ងៀមស្ងាត់ជាមួយក្រុមប្រជាជន ស្តាប់ខ្លឹមសារនេះទាំងជក់ជាប់ចិត្ត។ សមមិត្តប្រធានឆ្លៀតបន្ថែមសកម្មភាពជាក់ស្តែង នៅប្រទេសសង្គមនិយមដទៃទៀត ដែលសមមិត្តបានទៅធ្វើទស្សនកិច្ចជាផ្លូវការ។ សមមិត្តមានប្រសាសន៍ថាដូចជាប្រទេសអាល្លឺម៉ង់ គេជឿនលឿនខ្លាំងណាស់... ប្រជាជនគេឆ្លងគ្រោះមិនចេះអក្សរអស់រយៈពេលជាយូរឆ្នាំមកហើយ ហើយគ្មានប្រជាជនណាម្នាក់គ្មានការងារធ្វើនោះទេ។ សហករណ៍របស់គេមានអ្វីៗសព្វបែបយ៉ាងដែលទំនើប ហើយទាមទារឲ្យមនុស្សធ្វើការតែប្អូនប្រាំម៉ោងក្នុងមួយថ្ងៃ ក្រៅពីនោះ គឺគេសម្រាកដើរកម្សាន្ត។ ចំណែកឯប្រទេសយើងក៏មានគោលបំណងអនុវត្ត ដូចប្រទេសជឿនលឿនទាំងនោះដែរ... តែការដែលយើងទើបរំដោះថ្មីៗនេះ អ្វីៗដែលខ្ទេចខ្ទីអស់គ្មានសល់យើងបានខំប្រឹងប្រែងស្តារឡើងវិញ។ មូលហេតុនេះហើយ បានជាយើងជួបប្រទះការលំបាកស្មុគស្មាញជាច្រើន។ ប៉ុន្តែទោះជាមានការលំបាកយ៉ាងណាក៏ដោយ ក៏ប្រជាជន និងរដ្ឋអំណាច ព្រមទាំងកងប្រដាប់អាវុធ រួមសហការធ្វើការងារវាយខ្នាំង

ដែលនៅសេសសល់ផង បង្កបង្កើនផលផង ដើម្បីគោលដៅតែមួយគឺ សន្តិភាព និងវឌ្ឍនភាព។

សំឡេងទះដៃលាន់រំពង ធ្វើឲ្យសមមិត្តប្រធានឈប់មួយរយៈតូច ដើម្បីទុកឱកាសឲ្យប្រជាជនសម្ដែងពីទឹកចិត្តត្រេកអររំភើបរបស់គេ ដោយស្នូរទះដៃជាសញ្ញានេះ។ ចប់ស្នូរទះដៃអបអរសាទរនឹងរបបថ្មីនេះហើយ សមមិត្តប្រធានក៏បន្តសម្ដីទៀត ៖

- ពេលនេះ បងប្អូនទាំងអស់បានយល់ពីអ្វីដែលជាគោលការណ៍នៃរបបសង្គមនិយមហើយ ហើយថ្ងៃជាបន្តៗទៀត បងប្អូននឹងបានយល់អំពីមុខជំនាញនីមួយៗដែលមិត្តយើងក៏មានមុខនៅទីនោះដែរ (សមមិត្តឆ្លៀតបង្ហាញកម្មាភិបាលដែលចុះពីមជ្ឈិមជូនដល់ប្រជាជនយើងឲ្យបានស្គាល់) និងរៀបរាប់លម្អិតខ្លឹមសារបន្ថែមទៀត ដើម្បីឲ្យបងប្អូនទាំងអស់ងាយស្រួលក្នុងការអនុវត្ត។ គោលការណ៍តែមួយរបស់បក្ស គឺអនុវត្តគ្រប់ទីកន្លែងទូទៅក្នុងទឹកដីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ស្នូរទះដៃជាលើកទីពីរកក្រើកឡើង ធ្វើឲ្យខ្ញុំចាប់អារម្មណ៍ដល់សំនួនវោហាររបស់សមមិត្តប្រធាន។ សមមិត្តមានប្រសាសន៍មួយៗ ពាក្យពេចន៍សាមញ្ញ ងាយយល់ងាយស្ដាប់ ហើយក្នុងនោះក៏មានបង្កប់នូវពាក្យកំប្លែង ដែលធ្វើឲ្យអ្នកស្ដាប់ទាំងអស់ឥតធុញទ្រាន់ ឬក៏ងោកងុយសម្រាន្តឡើយ។

នៅទីបញ្ចប់ សមមិត្តប្រធានបានប្រកាសជូនពរដល់ប្រជាជនទាំងអស់... ជូនពរដល់រដ្ឋអំណាចមូលដ្ឋាន ហើយប្ដេជ្ញាខិតខំឲ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីរៀបរាប់ពន្យល់ពីអ្វីដែលសមមិត្តបានចេះចាំ ជូនទៅដល់រដ្ឋអំណាចមូលដ្ឋានត្រងត្រាប់ និងឆាប់កសាងប្រទេសឲ្យបានឈានឡើងសម្បូររុងរឿង ដូចប្រទេសជឿនលឿន





លើសកលលោក។

សមមិត្តបានពោលអះអាងថា សមមិត្តមិនភ្លេច និងពាំនាំយកសំណូមពរទាំងឡាយរបស់ប្រជាជន ទៅរាយការជូនថ្នាក់លើឲ្យបានជ្រាបពីសុខទុក្ខ និងការលំបាកគ្រប់បែបយ៉ាង។ សមមិត្តបញ្ជាក់បន្ថែម ៖

- ក្រុមប្រតិបត្តិការនេះ គឺពិតជាស្ពានចម្លងពីមជ្ឈិមមកមូលដ្ឋាន និងពីមូលដ្ឋានទៅមជ្ឈិមវិញ។

ស្នូរទះដៃជាលើកទីបី ជាស្នូរទះដៃយ៉ាងយូរ មុននឹងបញ្ឈប់ជាស្ថាពរ។

ប្រជាជនម្នាក់ងាកមករកខ្ញុំ រួចសួរ ៖

- សមមិត្តនារី បងប្រធានឈ្មោះអ្វី?

ខ្ញុំឆ្លើយភ្លាមដោយពុំចាំបាច់រកនឹក ៖

- ឈ្មោះ សម្បត្តិ!

ខ្ញុំគិត ៖

- ប្រជាជនប្រហែលជាពេញចិត្តណាស់ហើយមើលទៅ បានជាចង់ស្គាល់ឈ្មោះប្រធានភ្លាមយ៉ាងនេះ។

ក្រោមរស្មីព្រះចន្ទ... ជំនោររាត្រីនៃទឹកដីដ៏មានជីវជាតិកាត់ថ្លៃពុំបាននេះ ធ្វើឲ្យខ្ញុំរីករាយក្នុងចិត្តពន់ប្រមាណ ស្ទើរតែរកពាក្យពេចន៍ថ្លាថ្លែងពីទឹកចិត្តរីករាយនោះពុំបាន... រួចគិតដល់សេរីភាពមួយ ដែលខ្ញុំរង់ចាំយ៉ាងអន្ទះអន្ទែងជាយូរមកហើយ ហើយឥឡូវ សេរីភាពនោះកំពុងស្ថិតក្នុងកណ្ដាប់ដៃរបស់ខ្ញុំ។

ខ្ញុំឥតត្រូវការអ្វីទៀតឡើយ... រួចទឹកមុខពិចិត្តដ៏ស្លូតបូតមកប្រត្យក្សក្នុងរង្វង់ផ្ទៃនៃដួងព្រះចន្ទ។ ប្រទេសបានរំដោះរួចពីបនប្រល័យពូជសាសន៍ហើយ... បាត់

បងទៅណា? គេទាំងអស់គ្នានឹកថា ខ្ញុំជាស្រីមេម៉ាយ... ត្រូវហើយ... ខ្ញុំឥតប្រកែកតវ៉ានឹងឈ្មោះដែលគេបន្ថែមក្រៅនេះឡើយ... ប៉ុន្តែមានតែពិចិត្តមួយទេដែលដឹងថា ខ្ញុំជាមាសទឹកដប់ក្រពុំបរិសុទ្ធ... ស្អាតឥតប្រឡាក់ប្រឡូស។

ទៅដល់កន្លែងសម្រាក សមមិត្តប្រធានបានរៀបចំកម្មវិធី ហើយចាត់តាំងជាបន្ទាន់ភ្លាមៗ សម្រាប់ការងារនៅវេលាថ្ងៃស្អែក។ ខ្ញុំចេះតែសង្កេតបងប្រធានរូបនេះមានប្រាជ្ញាវាងវៃណាស់ ព្រោះរបៀបចាត់ចែងការងារ សំនួនវោហារទន់ភ្លន់ ទោះបីជានិយាយរបៀបដាក់ទណ្ឌកម្មដល់សមាជិកណាមួយ ក៏សមាជិកនោះពុំមានកំហឹងតបតដែរ។

សមមិត្តលើកឡើងដើម្បីយករឿងមួយមកពិភាក្សារួម ៖

- ក្រុមយើងចុះមកពង្រឹងឃុំពីរ គឺ ឃុំដានេះ និងឃុំទ្រៀក... តាមបណ្តាំរបស់គណៈចាត់តាំងមជ្ឈិម គឺឲ្យយើងចែកជាពីរក្រុម មួយក្រុមនៅធ្វើការឃុំដា ឯមួយក្រុមទៀតត្រូវចុះទៅធ្វើការនៅឃុំទ្រៀក... តើអ្នកទាំងអស់គ្នាយល់យ៉ាងណាដែរ?

គ្រាន់តែសមមិត្តលើកសំណួរនេះភ្លាមកាលណា ខ្ញុំយល់ថា យី! សមមិត្តប្រធានមានប្រាជ្ញាវាងវៃម្ល៉េះ ខ្ញុំសែនពេញចិត្តនឹងបងប្រធានដ៏កម្រកបាននេះណាស់... ចុះគំនិតសមាជិកដទៃទៀត តើគេយល់យ៉ាងណាដែរ?

សមាជិកម្នាក់ឆ្លើយឡើង ៖

- បងប្រធានខ្ញុំសុំមានមតិ! តាមយោបល់ផ្ទាល់របស់ខ្ញុំ គឺខ្ញុំសំណូមពរឲ្យបងប្រធានធ្វើការងារនៅឃុំមួយចប់សិន សឹមលើកទៅឃុំមួយទៀត បានជាខ្ញុំសំណូមពរដូច្នេះ ពីព្រោះថា រូបខ្ញុំផ្ទាល់ ការចុះមកពង្រឹងមូលដ្ឋាននេះ គឺជាភារកិច្ចថ្មីថ្មោងបំផុត ដូច្នេះខ្ញុំចង់ឲ្យមានការពិភាក្សាឲ្យបានច្រើន សុភាសិតបុរាណមួយចែងថា





"គ្នាតិច គំនិតតិច... គ្នាច្រើន គំនិតច្រើន..." ម្យ៉ាងឃុំដែលយើងកំពុងឈរជើងនេះពុំមែនមានតែភូមិមួយឯណា គឺបានសេចក្តីថា មានភូមិច្រើន។ ដូច្នេះ ក្នុងឃុំនេះយើងចែករំលែកគ្នាយើងចុះទៅភូមិផ្សេងៗ តែលុះដល់ពេលយប់ យើងមកជួបជុំគ្នា យើងបានប្តូរយោបល់គ្នា ប្តូរបទពិសោធន៍ជាមួយគ្នា រួចយើងជ្រើសរើសទិសណាដែលល្អយកមកអនុវត្តបន្តទៀត។

សមមិត្តប្រធានមិនទាន់សម្រេចថាយ៉ាងណាៗនៅឡើយទេ ក៏ងាកមករកខ្ញុំមុនគេ ព្រោះសមមិត្តគោរពសិទ្ធិនារី ហើយសួរខ្ញុំ ៖

- តើសមមិត្តនារីយល់យ៉ាងណាដែរ ចំពោះយោបល់ខាងលើនេះ?

មុននឹងឆ្លើយ ខ្ញុំបានប្រកាសគោរពប្រធាន និងអង្គប្រជុំ រួចឆ្លើយ ៖

- យោបល់ខាងលើនេះស្របនឹងបំណងប្រាថ្នារបស់ខ្ញុំដែរ ដូច្នេះខ្ញុំពុំមានយោបល់អ្វីថ្លែងក្រៅពីយល់ព្រមទាំងស្រុងនោះទេ។

សមមិត្តប្រធានសួរបន្ត ៖

- ចុះអ្នកឯទៀតមានយោបល់យ៉ាងណាដែរ?

សមាជិកដទៃទៀតឆ្លើយ ៖

- យល់ព្រម! យល់ព្រម!

ដូច្នេះ ការបែងចែកជាពីរក្រុមត្រូវអាកខាន ព្រោះមតិភាគច្រើនមិនយល់ស្រប។

កិច្ចប្រជុំដ៏តូចនេះបានបញ្ចប់នៅម៉ោងដប់មួយអធ្រាត្រ រីឯអ្នកមានភារកិច្ចយាមមុនគេក៏ចាប់អនុវត្តឡើង។

ដោយសារការធ្វើដំណើរផ្លូវឆ្ងាយ ដោយរយៈពេលធ្វើដំណើរនេះ ខ្ញុំមានកង្វល់ទៅលើការនឹករឭកដល់គ្រាដើមច្រើនពេក... ដោយសារខ្យល់អាកាសបរិសុទ្ធនៃ

តំបន់ជនបទ ឬក៏ដោយសារឃុំនេះធានាសន្តិសុខ បានជាធ្វើឲ្យខ្ញុំលង់លក់ភ្លាមមួយរំពេច។

ភ្លឺឡើង ខាងសមាគមនារីបានចាត់ប្រធាននារីឲ្យមកទំនាក់ទំនងការងារជាមួយខ្ញុំ។ យើងស្គាល់រាប់អានគ្នាមួយរំពេច ព្រោះភាសាយើងដូចគ្នា សម្បុរយើងដូចគ្នា ហើយមានឈ្មោះរួមគ្នាថា ជនជាតិខ្មែរដូចគ្នា។

សម្តីអ្នកកំពង់ចាមគួរឲ្យកត់សម្គាល់ម៉្យាងដែរ យើងទាំងពីរនាក់ឆាប់ត្រូវគ្នាណាស់ ប្រហែលជាចិត្តគំនិតយើងដូចគ្នាក៏មិនដឹង។ ប្រធានសមាគមនារីឃុំឈ្មោះ "ភួង" នៅលីវ នាងមានអាយុតិចជាងខ្ញុំច្រើន ប៉ុន្តែនាងមានមាឌខ្ពស់ស្រឡះ សក់ស្លូត ទម្រង់មុខពងក្រពើ... ពេលនាងសើចម្តងៗ មុខគួរឲ្យចង់គយគន់ ព្រោះនាងមានសម្រស់ជានារីខ្មែរ...។ ភួងរស់នៅជាមួយម្តាយមេម៉ាយ មានប្អូនប្រុសម្នាក់ដែរ ប៉ុន្តែបែកគ្នាតាំងពីសម័យ ប៉ុល ពត ម្ល៉េះ។ ម្តាយភួងយកចិត្តទុកដាក់ជួយផ្គត់ផ្គង់ម្ហូបចំណីដល់ក្រុមប្រតិបត្តិការមជ្ឈិមណាស់ ដោយពុំមានខ្លាចនឿយហត់បន្តិចណាឡើយ។ ភួងសួរខ្ញុំ ៖

- បងស្រីមានគ្រួសារហើយឬនៅ?

ខ្ញុំឆ្លើយ ៖

- មានហើយអូន... ប៉ុន្តែបែកគ្នា...

ពាក្យប៉ុន្មានម៉ាត់នេះធ្វើឲ្យភួងយល់ថា ខ្ញុំជាស្រីមេម៉ាយស្រេចទៅហើយ។

ភួងសួរបន្ថែម ៖

- អត់ទោសបងឈ្មោះអី?

ខ្ញុំឆ្លើយ ៖





- បងឈ្មោះ "ឃុន"។

ភួងឧទានដូចភ្ញាក់ ៖

- អា៎! បងឈ្មោះដូចប្រុស។

ខ្ញុំសើចញឹមៗ ហើយឆ្លើយតប ៖

- បងឈ្មោះដូចប្រុសអ៊ីចឹង បានជាបងចុះមកមូលដ្ឋានដូចប្រុស... ក្លាហានដូចប្រុសអ៊ីចឹង។

ភួងសើចនឹងពាក្យខ្ញុំដែលមិនទាំងកំប្លែងផង មិនដឹងជានិស្ស័យអ្វីបានជាធ្វើឲ្យភួងយកចិត្តទុកដាក់រូបខ្ញុំខ្លាំងម្ល៉េះ រហូតដល់នាងបានទុកផ្លែឈើនិចំណីឲ្យខ្ញុំហូបពុំមានខ្វះ។ ឃុំជាដែលខ្ញុំស្នាក់នៅ ជាឃុំដែលសម្បូរផ្លែឈើណាស់ ជាពិសេសរដូវដែលខ្ញុំចុះទៅនេះ ជារដូវខ្នុរទុំ ដូច្នេះខ្ញុំហូបខ្នុរពុំដែលលោះពេលណាឡើយ។ មិនយូរប៉ុន្មាន ខ្ញុំក៏មានសាច់ជាងនៅភ្នំពេញ។ រីឯការងារក៏ចេះតែប្រព្រឹត្តទៅជាប្រក្រតី។ ថ្ងៃមួយ សមមិត្តប្រធានហៅខ្ញុំមកប្រាប់ថា ៖

- ស្អែក យើងត្រូវចុះទៅភូមិស្ពាន ចម្ងាយពីភូមិដានេះចំនួនប្រាំបីគីឡូម៉ែត្រ (៨ គ.ម.) សមមិត្តនារីឃុនពុំចាំបាច់ចុះទៅទេ ព្រោះឆ្ងាយណាស់ ម៉្យាងយើងត្រូវវិលល្ងាចផង ដូច្នេះក្រែងលោសមមិត្តនារីពុំអាចធ្វើដំណើរទៅបាន។

ខ្ញុំគ្រវីក្បាលប្រកែក ហើយឆ្លើយថា ៖

- មិនអីទេបងប្រធាន! ខ្ញុំអាចដើរបានដូចគេទាំងអស់គ្នាដែរ... ខ្ញុំសុំចុះទៅផង។

សមមិត្តប្រធានពុំនិយាយថាយ៉ាងណា ប៉ុន្តែគាត់ងក់ក្បាលទទួលយល់ព្រមចម្លើយរបស់ខ្ញុំ។ ព្រឹកឡើង យើងទាំងអស់គ្នាភ្ញាក់ពីព្រលឹមងងឹត។ ខ្ញុំក្រោកស្លៀកពាក់រង់ចាំការចេញដំណើរ រំពេចនោះនាងភួងក៏មកដល់ល្មម។ ខ្ញុំនឹកឆ្ងល់ក្នុងចិត្ត

ហេតុអ្វីក៏ភួងដឹង? បើខ្ញុំមិនបានប្រាប់ផង ប៉ុន្តែខ្ញុំឥតសួរនាំអ្វីទាំងអស់ រួចគំនិតមួយទៀតគិតថា ៖

- រឿងនេះ គេជាអ្នកមូលដ្ឋាន គេក្តាប់សភាពការណ៍ច្បាស់ណាស់ មិនចាំបាច់ខ្ញុំឆ្ងល់ច្រើនទេ។

ភួង និងខ្ញុំ យើងធ្វើដំណើរដោយឥតមានកាន់អ្វីទាំងអស់ បានសេចក្តីថាសមមិត្តប្រធានមិនឲ្យយើងកាន់កាំភ្លើង ឯពួកប្រុសៗ គេមានកាន់កាំភ្លើងគ្រប់ដៃ។ នេះជាការប្រុងប្រយ័ត្នចំពោះពួកបិសាចហុតឈាម ដែលយើងនៅមិនទាន់បោសសម្អាតឲ្យអស់រលីងពីលើទឹកដីកម្ពុជា។ ពួកវានៅតែស្រមើស្រមៃខិតខំតស៊ូដោយផ្សងព្រេងប្រាថ្នាវិលមកកាន់កាប់រដ្ឋអំណាចជាថ្មីម្តងទៀត។ ប៉ុន្តែកិច្ចការនេះយើងបានដឹងពីគំនិតដ៏លោភលន់របស់ពួកវាអស់ហើយ ហើយខ្ញុំនៅចាំឥតភ្លេចសោះ នៅពេលដែលកងទ័ពរណសិរ្សរួមសហការជាមួយនឹងកងទ័ពវៀតណាម មករំដោះប្រជាជនកម្ពុជាទូទាំងប្រទេសឲ្យរួចផុតពីក្រញាំបិសាច ហើយកាលនោះ ខ្ញុំនៅក្នុងកណ្តាប់ដៃពួកវា ពួកវាបានវាស់ដីឲ្យខ្ញុំ និងប្រជាជនឯទៀតដើរ បានសេចក្តីថា វាមិនឲ្យយើងដើរហើរតាមចិត្តយើងទេ មូលហេតុនេះហើយបានជាខ្ញុំពុំបានដឹងថា អ្វីៗរបស់ប៉ុល ពត វាសម្បើមប៉ុនណាទៅ វាខ្លាំងប៉ុនណាទៅ វាអស្ចារ្យដូចម្តេចទៅ ឬកពួកវានេះពូកែតែអួត តែតាមពិតរាក់កំភែល។

ខ្ញុំលាតត្រដាងអំពីជំរំមូលដ្ឋានធំរបស់ពួកវាមួយ ដែលកាលខ្ញុំនៅក្នុងសម័យរបស់ពួកវា ខ្ញុំបាននឹកថា ប្រហែលជាជំរំនោះមានលំនាំប្រហាក់ប្រហែលដូចជាទីក្រុងមួយល្អឆើតឆាយ ភ្លើងភ្លឺចិញ្ចាចចិញ្ចែងនៅពេលយប់ អ៊ូអែរគគ្រឹកគគ្រេង ប៉ុន្តែផ្ទុយទៅវិញសោះ។



# ៥. ក្មេងជួបក្អាត់ក្នុងក្អម

ថ្ងៃប្រាំពីរ មករា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួន (០៧.០១.១៩៧៩) ភ្នំពេញបានរំដោះហើយ ប៉ុន្តែស្រុក ឃុំ ភូមិ ខ្លះនៅមិនទាន់បានរំដោះនៅឡើយទេ។ ខ្ញុំនឹកឃើញមីងម៉ៅ ខ្ញុំនិងគ្រួសារមួយដែលមានសមាជិកបីនាក់ គឺ ប្តី ប្រពន្ធ និងកូនតូចម្នាក់ បានធ្វើដំណើរដោយឥតមានគោលដៅ ឆ្ពោះទៅទិសខាងលិច។

ខ្ញុំឥតដឹងថា មានសភាពការណ៍យ៉ាងណាទេ កាលពីពេលមុននោះ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា ពួកវាឲ្យយើងចេញពីភូមិ ពីព្រោះបន្តិចទៀតនឹងមានការត្រៀមប្រយុទ្ធ។ មីងម៉ៅ ខ្ញុំ និងគ្រួសារមួយរៀបចំអីវ៉ាន់បន្តិចបន្តួច ដាក់លើរទេះគោមួយប្រុងប្រៀបចេញដំណើរទៅ។ គ្រួសារនេះមានលំនៅជិតខ្ញុំដែរ ហើយគាត់រាប់អានខ្ញុំ និងមីងម៉ៅណាស់ ដូច្នេះហើយបានជាដល់ពេលចេញដំណើរពីភូមិ គាត់បានហៅខ្ញុំ និងមីងម៉ៅឲ្យទៅជាមួយគាត់។ ខ្ញុំនឹកគុណអ្នកជិតខាងឥតភ្លេចសោះ ព្រោះបើគាត់មិនជួយយកអាសាទេ ម្ល៉េះសមខ្ញុំមានការលំបាកលំបិនយ៉ាងណាក្នុងការរែកពុនអង្ករ និងអីវ៉ាន់អីវ៉ាន់ទៅតាមផ្លូវដ៏សែនឆ្ងាយឥតទីកំណត់ឥតព្រាងទុក។ រាត្រីដប់បីកើត (១៣ កើត) ខ្ញុំរៀបចំអីវ៉ាន់ដាក់រទេះទឹមដោយគោកញ្ចាស់មួយគូ មានគោលបំណងនឹងចរយាត្រាឆ្ពោះទៅទិសខាងលិច គេចពីពួកខ្មាំងសត្រូវ និងគ្រាប់រំសេវផងទាំងពួង។

សំឡេងចាប់មាន់ ក្មេងក្មាងយំ ម្តាយស្រែកប្រកូកប្រកាសហៅប្រមូលកូនចៅ ដើម្បីចេញដំណើរជុំគ្នា។ សំឡេងបុរសៗដេញគោដែលសហករណ៍គេចែកឲ្យមួយនឹមៗ មួយគ្រួសារសម្រាប់ធ្វើស្រែចម្ការ។ ពីរបីគ្រួសារជិតខាងខ្ញុំ គេចេញដំណើរទៅមុនខ្ញុំស្ងាត់អស់ហើយ។ នៅតែក្រុមខ្ញុំ និងរទេះគោមួយនឹមនេះ។ ជាការធម្មតារបស់ខ្ញុំរៀងរាល់លើក សឹងតែជាទម្លាប់ទៅហើយ ដែលខ្ញុំជាមនុស្សយឺតយ៉ាវ និងពពីមពពើមផង។ ពូសន ប្តីមីងសួន រៀបចំអីវ៉ាន់រួចហើយ ក៏និយាយតឿនខ្ញុំឲ្យរហ័សដៃរហ័សជើងបន្តិច ត្បិតអ្នកជិតខាងគេទៅស្ងាត់អស់ហើយ។ ខ្ញុំចេញចូលៗហាក់ដូចជាពុំចង់ឃ្លាតចេញពីផ្ទះកម្សត់នេះសោះ។ ខ្ញុំនឹកស្រណោះដល់កន្លែងដែលខ្ញុំធ្លាប់ជ្រក។ ពេលចេញមកដល់វាល ខ្ញុំងើបមើលព្រះចន្ទ និងហ្វូងតារាដែលរះពេញពាសផ្ទៃមេឃា ប្រៀបហាក់បីដូចជាកម្រាលព្រំពណ៌ខៀវក្រមៅ បន្តក់ដោយត្បូងពេជ្រទាំងគ្រាប់ ចាំងរស្មីព្រិចៗគួរឲ្យគយគន់។ ខ្យល់ត្រជាក់ពេលរាត្រីដែលជាជំនោរទិព្វសណ្តំសត្វលោក ឲ្យលង់លក់យ៉ាងសុខស្រួលពេលទៀបភ្លឺនេះ មិនគួរណាឡើយ យើងនាំគ្នាឃ្លាតចាកពីទ្រនំដ៏សែនកក់ក្តៅនេះសោះ។

យើង និងគ្រួសារអ្នកដទៃទៀត នាំគ្នាធ្វើដំណើររសឹបរសាវកាត់ជំនោររាត្រី ឆ្ពោះទៅទិសខាងលិច ដោយឥតព្រាងទុក ឥតគោលដៅ។

ខ្ញុំឃើញយន្តហោះសង្កេតការណ៍ ហោះឆ្វៃលឆ្វាត់ពីលើក្បាលយើង។ ពូសនរៀបនឹងរកកន្លែងចតរទេះ ដើម្បីពិនិត្យមើលស្ថានការណ៍ និងដើម្បីជ្រកពួន ប៉ុន្តែពូសនបែរជានិយាយ ៖

- ទៅ! យើងប្រឹងស្រូតរូតដំណើរបន្តិច ព្រោះកងទ័ពបាននិយាយប្រាប់ថា បើពួកយួនវាមកទាន់ វានឹងសម្លាប់យើងដោយការធ្វើទារុណកម្មផ្សេងៗ ដូចជាចោះ





ដៃដោតខ្សែ... វះពោះញាត់ស្មៅ... យកដែកគោលចោះត្រចៀក បើកូនក្មេងវិញ គឺបោះឡើងទៅលើ ហើយយកចុងកាំភ្លើងទ្រចាក់ទម្លុះពីក្រោម។ ខ្ញុំឮពូសននិយាយពីទណ្ឌកម្មដ៏សែនឃោរឃៅយ៉ាងនេះ ក៏តឿនពូសនឲ្យប្រញាប់ស្រូតរូតដំណើរទៅមុខទៀត កុំឲ្យនៅបង្អង់យូរ ក្នុងលក្ខណៈបាក់ស្បាតផ្អែកស្មារតី ។

ខ្ញុំលើកដងរែកឡើងរែក (ការដែលខ្ញុំរែកអីវ៉ាន់ខ្លះយ៉ាងនេះ គឺមានបំណងចង់ជួយសម្រាលទម្ងន់គោកញ្ចាស់។ នៅលើរទេះ ខ្ញុំផ្ញើអង្ករពូសនតែមួយស្បោងតែប៉ុណ្ណោះ ក្រៅពីនោះខ្ញុំរែកទាំងអស់)... យើងចេញដំណើរបានប្រហែលមួយស្រែស្រាប់តែលាន់ក្តឹងឡើងស្ទើរកក្រើកប្រថពី... ខ្ញុំភ័យបាក់លោង ដួលទាំងជំហរទាំងដងរែកនៅលើស្មា...។ ពូសន គាត់ធ្លាប់ធ្វើទ័ពកាលពីសម័យ លន់ នល់ ក៏ស្រែកខ្លាំងៗភ្លាត់សំឡេងថា ៖

- ទៅមុខ... គ្រាប់ផ្ទុះ មិនមែនការប្រយុទ្ធទេ ប៉ុន្តែគោកញ្ចាស់របស់ពូសន វាឥតភ័យឥតផ្អើលដូចពូសនទេ... វានៅតែដើរយឺតៗដូចធម្មតា។ ខ្ញុំងើបឡើង... ខ្លួនប្រាណប្រឡាក់ដីស្រមក ហើយក៏ប្រញេបប្រញាប់លើកដងរែកធ្វើដំណើរទៅមុខទៀត ទាំងបេះដូងយោលរណ្តំពេញដើមទ្រូង ព្រមទាំងភ័យញ័រចំប្រប់។ ខ្ញុំឮស្នូរគ្រឹកគ្រាក់ៗ... ហើយនឹកថា មានកងទ័ពអីសម្បើមម្លេះ។

ពេលយប់យើងឈប់សម្រាកនៅក្រោមដើមឈើ... យើងចតរទេះហើយរៀបចំកន្លែងសម្រាន្ត... ខ្ញុំឃើញគ្រួសារអ្នកដទៃ... អ្នកជន្លៀសដូចខ្ញុំដែលស្នាក់នៅទីនោះព្រាងព្រាត។ ចង្កៀង ឬចន្លុះអុជផ្លុងៗ មើលទៅដូចជាជំរំទេសចរណ៍ណាមួយដែលគេទៅកម្សាន្តយកខ្យល់អាកាស វេលាមហាវិស្សមកាលនៃរដូវក្តៅ... ហ៊ឺ! ម្លេះសមពោរពេញទៅដោយក្តីសប្បាយយ៉ាងណាទេ... តែ... ខ្លឹមសារនៃជំរំទេសចរណ៍

ពេលនេះ បើយើងដឹងការពិតទៅវិញនោះ គឺការព្រាត់ប្រាសផ្ទះសម្បែង បែកម៉ែឪ... បងប្អូន... ប្តីប្រពន្ធ... កូនចៅ មុខគួរឲ្យសង្វេគអនិច្ចាអាណោចអធ័មទៅវិញទេ។

ខ្ញុំដេកក្រោមដើមឈើកណ្តាលវាល ហាលខ្យល់ ហាលសន្សើម នឹកស្រណោះដល់ម្តាយទាំងឡាយដែលមានកូនតូចនៅអឹមដោះ។ កណ្តាលអធ្រាត្រ ខ្ញុំភ្ញាក់ឡើង បើកភ្នែកមើលដើមឈើតូចធំ ដែលដុះឥតសណ្តាប់ធ្នាប់កណ្តាលទ្រូងព្រៃ ផរាំពត់ពេនតាមកម្លាំងខ្យល់បក់ ក្រោមរស្មីដ៏ស្រទន់នៃព្រះចន្ទ្រា ហាក់បីដូចជានាដការិនីដ៏ល្អសោភា នាទេវដ្ឋាន។ ខ្ញុំដេកបណ្តែតអារម្មណ៍ឲ្យអណ្តែតត្រសែតទៅឆ្ងាយៗ ហួសនិស្ស័យនឹងរកទីកំណត់ពុំបាន។ ឱ! ថ្ងៃនេះ ហេតុដូចម្តេចបានជាខ្ញុំមកដេកកណ្តាលទ្រូងព្រៃដូច្នេះទៅវិញ។ ខ្ញុំងាកទៅព្រៃគុម្ពោតដែលនៅក្បែរៗខ្ញុំ ខ្ញុំក៏ឃើញគេដេកដូចខ្ញុំដែរ គ្រាន់តែគេភ្ញាក់ ឬក៏លក់តែប៉ុណ្ណោះ ហើយបើគេភ្ញាក់ គេមានគិតដូចខ្ញុំទេ? ឱ! ពុទ្ធោអើយ ស្អែកឡើង យើងត្រូវធ្វើដំណើរទៅមុខទៀត មិនដឹងជាទៅមុខ ទៅទីណា ប្រាថ្នាទៅធ្វើអ្វី គឺយើងពិតទៅជាផ្សងព្រេងមែនហើយ។

កាលពីឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ (១៩៧៥) កងទ័ព ប៉ុល ពត វាដេញយើងឲ្យចុះចេញពីផ្ទះសម្បែង ពីភូមិឋាន ពីស្រុកកំណើត ពេលនោះ ខ្ញុំបែកបាក់ខ្ចាតខ្ចាយពីគ្រួសារ ហើយរសាត់អណ្តែតមកដល់ស្រុកត្រពាំងធំដោយចៃដន្យ តែពេលនេះ ពុទ្ធោអើយ! ខ្ញុំត្រូវទៅណាទៀត បើក្នុងខ្លួនខ្ញុំឥតមានបំណងទៅណាផង ទៅភ្នំពេញឬ?... ទេ ទៅអង្គតាសោមឬ? ទេ ទៅបាត់ដំបងឬ? ទេ ទៅសៀមឬ? ទេ ចុះបើទេដូច្នេះ តើខ្ញុំបង្ខំជើងឲ្យដើរទៅមុខទៅទិសខាងលិច (ពេលជន្លៀសនោះ គឺខ្ញុំដើរមកទិសខាងលិច) ទៅរកអីនៅទីនោះ បើខ្ញុំគ្មានបងប្អូនឯណាទៀតផង ខ្ញុំក៏មិនយល់ខ្លួនឯងដែរ។ ខ្ញុំធ្វើដំណើរពេលនេះ គឺខ្ញុំដើរកាត់ទ្រូងព្រៃតែម្តង





មិនមែនដើរតាមផ្លូវជាតិទេ ដូច្នេះខ្ញុំចាត់ទុកថា ខ្ញុំជាជនមានភ័ព្វសំណាង បានដើរគយគន់ទេសភាពនៃមាតុប្រទេសជាទីស្នេហានៃខ្ញុំទៅចុះ ក្នុងនាមជាអ្នកជន្លៀសជាថ្មីម្តងទៀត។

នៅពាសពេញព្រៃ ខ្ញុំសង្កេតឃើញមានជំរំដែលអ្នកជន្លៀសណាមកដល់ទីនេះមុនគេ ក៏កាប់មែកឈើ ស្លឹកឈើសង់ជាកូនរោងតូចៗសម្រាប់ជ្រក ឬសម្រាកពេលយប់។ ដូច្នេះហើយបានជានៅស្ទើរតែគ្រប់ទីកន្លែង កាលណាខ្ញុំទៅដល់ គឺមានលេណដ្ឋាន និងជម្រករួចជាស្រេច គ្រាន់តែយើងយកមែកឈើថ្មីមកដាក់ថែមថយព្រោះស្លឹកឈើ កាលណាកាច់មករយៈពេលបីបួនថ្ងៃ វាស្វិតស្រពោន ដូច្នេះអ្នកមកជ្រកថ្មីត្រូវបន្ថែមស្លឹកថ្មី។ រោងតូចៗប្រក់ទៅដោយស្លឹករុក្ខជាតិនេះ បង្កើតបាននូវភាពសប្បាយរីករាយម្យ៉ាងដែរ ប្រសិនបើយើងជាទេសចរដើរកម្សាន្តពិតប្រាកដមែន។

ខ្យល់បក់មកល្មៀកៗ ត្របកភ្នែកទន់ទៅៗរហូតដល់លង់លក់ដោយភ្លេចសូន្យសុងពីរឿងយួន ពីរឿងទៅសៀម ភ្លេចមីងម៉ៅ ពូសន មីងសួន និងសម្បត្តិទ្រព្យបន្តិចបន្តួចដែលដាក់លើរទេះ ព្រមទាំងគោកញ្ចាស់មួយនឹមដែលចងក្បែរខាង។ ឱ! គិតទៅ មនុស្សដេកលក់ប្រៀបដូចជាគល់ឧសសុទ្ធសាធ។ ហេតុអ្វីក៏មនុស្សចិត្តអាក្រក់ម្ល៉េះ ឈ្នានីសគ្នា បើស្លាប់ទៅពុំបាននាំអ្វីទៅតាមខ្លួន សូម្បីតែបន្តិចក៏គ្មានផង ហេតុដូចម្តេចក៏គេកាប់សម្លាប់គ្នា សង្កត់សង្កិនគ្នា ខ្ញុំពុំយល់ពីគំនិតនេះទេ ក្រែងយើងរស់ក្រោមផ្ទៃមេឃតែមួយ ជំពាក់ផែនដីដូចគ្នា ចាំបាច់មានឋានសួគ៌ ឋាននរក នាំតែឲ្យសៅហ្មងដល់ជីវិតរស់នៅ រួចនៅទីបំផុត នរណាក៏ត្រូវតែសងបំណុលផែនដីចៀសមិនរួច ទោះជាអ្នកនោះមានអំណាចបុណ្យសក្តិ ទ្រព្យសម្បត្តិ ស្តុកស្តម្ភ ឬក៏

ទោះជាអ្នកនោះក្រខ្សត់ តោកយ៉ាក លំបាកវេទនាយ៉ាងណាក៏ដោយ ក៏ត្រូវតែបង់វិភាគទានជូនផែនដីជាសាច់ ជាឆ្អឹង ជាដាច់ខាត នឹងខកខានពុំបាន។

សំឡេងមាន់រងាវហើយ ពិតជាមាន់ស្រុក (មាន់ដែលអ្នកជន្លៀសយកទៅជាមួយទុកសម្រាប់ធ្វើម្ហូប) និងមាន់ព្រៃរងាវលាន់ទ្រហឹងអឺងកងរំពងឡើង លាយឡំគ្នាបំណាងដាស់ប្រជាជនឲ្យភ្ញាក់ឡើងប្រកបការងារ។ ខ្ញុំនិងគ្រួសារអ្នកដទៃមានការងារអ្វីធ្វើ? បើយើងកំពុងតែរត់គេចពីសង្គ្រាម ពីចុងអាវុធ ពីគ្រាប់រំសេវយ៉ាងនេះ យើងគ្មានការងារអ្វីធ្វើក្រៅពីរត់ទៅមុខទេ។

បុរសខ្លះដែលមានទម្លាប់ក្រោកពីយប់ ក៏ភ្ញាក់ឡើងជក់បារីបង្ហុយផ្សែងបណ្តែតអារម្មណ៍គិតវែងឆ្ងាយ មិនដឹងជាគេគិតដល់ណា!

ដោយគ្មានការងារអ្វីធ្វើធំដុំ ខ្ញុំក៏នៅដេកដំអក់ កាលបើត្រូវខ្យល់ត្រជាក់ស្រួលពេលព្រហាម ក៏លង់លក់មួយភាំងទៀត ទើបភ្ញាក់ឡើង ខ្ញុំហាក់ដឹងថាមានកម្តៅឧណ្ហៗកាត់តាមប្រឡោះស្លឹករុក្ខជាតិមកប៉ះខ្លួន បង្ខំចិត្តឲ្យខ្ញុំក្រោកឡើង ទោះជាមិនទាន់អស់ងងុយក៏ដោយ... ហើយយើងបន្តដំណើរទៅមុខទៀត។

នៅចំពោះមុខយើងគឺ "បុសផង់" ។ ខ្ញុំចង់ឃើញបុសផង់នេះណាស់ ព្រោះកាលខ្ញុំនៅធ្វើការងារឯភូមិ ខ្ញុំឮតែឈ្មោះ "បុសផង់ៗ" ហាក់ដូចជាសម្បើមណាស់។ គេថាបុសផង់មានមូលដ្ឋានសំខាន់ៗ មានអគ្គិសនី និងមានអ្វីៗគ្រប់យ៉ាងទាំងអស់ គឺជាមូលដ្ឋានកងទ័ពជាជំរំគណៈធំៗស្នាក់នៅ ទីនោះមានផ្លូវខ្វាត់ខ្វែងដូចជាទីក្រុង។ ខ្ញុំនឹកក្នុងការស្រមៃថា បែបបុសផង់ល្អប្រណិតហើយមើលទៅ។ អារម្មណ៍ខ្ញុំអណ្តែតត្រសែតទៅរកបុសផង់មុនការទៅដល់ ស្រាប់តែនេះនែ! យើងមកដល់បុសផង់ហើយតើមានអ្វីគួរឲ្យអស្ចារ្យ ក្រៅពីមានផ្ទះតៀមឈើតូចៗទាបៗជាប់នឹងដី ប្រហែលជា





ប្អូនដប់ផ្ទួរដូចសាលារៀនអ៊ីចឹង មានបង្គោលអគ្គិសនីបន្តិចបន្តួច មានផ្ទៃដីប្រហែលជាពីរហិចតា ម្តេប្រាំសង់ទីអាតែប៉ុណ្ណោះ។ ខ្ញុំបានកត់សម្គាល់នូវចរិតរបស់ពួក ប៉ុល ពត ចំនួនពីរកន្លែងហើយ គឺទីមួយផ្នែកកងទ័ព ទីពីរផ្នែកមូលដ្ឋានបុសផង់នេះឯង។ ពួក ប៉ុល ពត នេះ បើសិនមិនបានស្គាល់ច្បាស់ទេ មុខជាភ័យខ្លាចមិនខាន ព្រោះរូបភាពរបស់ពួកវាខាងក្រៅ មើលទៅដូចជាសម្បើមខ្លាំងណាស់ ចំណែកឯខ្លឹមសារខាងក្នុងវិញ រាក់កំភែលនៅលើគោក គ្មានអ្វីគួរឲ្យអស្ចារ្យបន្តិចណាសោះ។ នេះបានប្រាកដដូចជាសត្វក្អាត់នៅក្នុងក្អមអ៊ីចឹង។